| ស្រី | ១០៩០ | ៦៩៩ |
| ចំនួនគ្រូបង្រៀន សរុប | ១៣៦ | ១២២ |
| ស្រី | ៧៣ | ៧៩ |

**១.៤ការងារយុវជន និងកុមារ**

| បរិយាយ | ឆ្នាំសិក្សា២០១៥ -២០១៦ | ឆ្នាំសិក្សា២០១៦-២០១៧ |
|---|---|---|
| ក្រុមប្រឹក្សាយុវជនវិទ្យាល័យ | ២ | ២ |
| ក្រុមប្រឹក្សាកុមារអនុវិទ្យាល័យ | ៨ | ៨ |
| ក្រុមប្រឹក្សាកុមារបឋមសិក្សា | ៥៨ | ៥៨ |
| សាខាវិទ្យាល័យ | ១១ | ១២ |
| សាខាអនុវិទ្យាល័យ | ៥០ | ៥០ |
| សាខាបឋមសិក្សា | ១៧៥ | ១៧៩ |
| អនុសាខាវិទ្យាល័យ | ៦០ | ៧២ |
| អនុសាខាអនុវិទ្យាល័យ | ១៩៣ | ២២៧ |
| អនុសាខាបឋមសិក្សា | ៧១២ | ៨៣៣ |

**១.៥ ការងារអប់រំកាយនិងកីឡា**

| | | |
|---|---|---|
| ប្រកួតកីឡាថ្នាក់ស្រុក | ១ | ១ |
| ប្រកួតកីឡាថ្នាក់ខេត្ត | ១ | ១ |
| ប្រកួតកីឡាថ្នាក់ទូទាំងប្រទេស | ១ | ០ |

**១.៦ ការងារអប់រំក្រៅប្រព័ន្ធ**

| | | |
|---|---|---|
| **ក.កម្មវិធីអក្ខរកម្ម** | | |
| ចំនួនថ្នាក់រៀន | ៤ | ៤ |
| ចំនួនសិស្ស សរុប | ៨៤ | ៨២ |

| | | | |
|---|---|---|---|
| | ស្រី | ៥២ | ៥៥ |
| ចំនួនគ្រូបង្រៀន | សរុប | ៤ | ៤ |
| | ស្រី | ១ | ២ |
| សិស្សឡើងថ្នាក់ | សរុប | ៥៦ | ៥៣ |
| | ស្រី | ៣៨ | ៤០ |
| សិស្សបោះបង់ | សរុប | ២៨ | ២៩ |
| | ស្រី | ១៤ | ១០ |
| **ខ.កម្មវិធីសមមូល** | | | |
| ចំនួនថ្នាក់រៀន | | ០ | ០ |
| ចំនួនសិស្ស | សរុប | ០ | ០ |
| | ស្រី | ០ | ០ |
| ចំនួនគ្រូបង្រៀន | សរុប | ០ | ០ |
| | ស្រី | ០ | ០ |
| សិស្សរៀនចប់ឆ្នាំ | សរុប | ០ | ០ |
| | ស្រី | ០ | ០ |
| សិស្សបោះបង់ | សរុប | ០ | ០ |
| | ស្រី | ០ | ០ |
| **គ.កម្មវិធីមជ្ឈមណ្ឌលសិក្សាសហគមន៍** | | | |
| ចំនួនថ្នាក់រៀន | | ៣ | ៣ |
| ចំនួនសិស្ស | សរុប | ០ | ៤២ |
| | ស្រី | ០ | ២៩ |
| ចំនួនគ្រូបង្រៀន | សរុប | ៣ | ៣ |
| | ស្រី | ៣ | ២ |
| សិស្សរៀនចប់ឆ្នាំ | សរុប | ២៨ | ៣៦ |
| | ស្រី | ២៨ | ៣៦ |

Remove Watermark Now

| | | | |
|---|---|---|---|
| សិស្សបោះបង់ | សរុប | ៧ | ៦ |
| | ស្រី | ៧ | ២ |

**១.៧ ការងារបុគ្គលិក**

| | |
|---|---|
| សំណើសុំតែងតាំងដោយព្រះរាជក្រឹត្យ ក្របខ័ណ្ឌ.ក | ២ |
| សំណើសុំតែងតាំងដោយអនុក្រឹត្យ ក្របខ័ណ្ឌ.ក | ១០ |
| សំណើសុំតែងតាំងដោយប្រកាស ក្របខ័ណ្ឌ.ក | ១៦ |
| ក្របខ័ណ្ឌ.ខ | ១៧៨ |
| ក្របខ័ណ្ឌ.គ | ២៩៦ |
| **សរុប** | ៥០៣ |

**១.៨ ការងារគណនេយ្យ**

| ថវិកាខេត្តផ្ទេរ | **ឆ្នាំសិក្សា 2015-2016** | **ឆ្នាំសិក្សា 2016-2017** |
|---|---|---|
| - ថវិកាដំណើរការការិយាល័យ | 12,500,000 | 17,400,000 |
| ថវិកាចំណាយ | 8,604,000 | 12,970,000 |
| ថវិកានៅសល់ | 3,896,000 | 4,430,000 |
| | | |
| ថវិកាខេត្តផ្ទេរ | | |
| - ថវិកាដំណើរការសាលាបឋមសិក្សា | 172,873,000 | 221,318,100 |
| - ថវិកាដំណើរការសាលាមធ្យមសិក្សា | 65,690,000 | 80,734,000 |
| **សរុប** | **238,563,000** | **302,052,100** |
| ថវិកាចំណាយ | | |
| - ថវិកាដំណើរការសាលាបឋមសិក្សា | 172,462,000 | 221,231,800 |
| - ថវិកាដំណើរការសាលាមធ្យមសិក្សា | 64,794,500 | 80,422,000 |
| **សរុប** | **237,256,500** | **301,653,800** |

iSkysoft

### ៣.៨.៣. ក្រុង ក្រចេះ

| ល.រ | ឈ្មោះតាមផ្នែក | ឆ្នាំសិក្សា ២០១៥-២០១៦ | ឆ្នាំសិក្សា ២០១៦ -២០១៧ |
|---|---|---|---|
| I | **ផ្នែកអប់រំកុមារតូច** | | |
| 1 | **មត្តេយ្យសិក្សារដ្ឋ** | | |

Remove Watermark Now

| | | | |
|---|---|---|---|
| | ចំនួនសាលា | 7 | 7 |
| | ចំនួនថ្នាក់ | 19 | 20 |
| | ចំនួនកុមារ | 683/327 | 704/339 |
| | ចំនួនគ្រូបង្រៀន | 32/32 | 32/32 |
| **2** | មត្តេយ្យសិក្សាឯកជន | | |
| | ចំនួនសាលា | 3 | 3 |
| | ចំនួនថ្នាក់ | 5 | 5 |
| | ចំនួនកុមារ | 169/73 | 168/73 |
| | ចំនួនគ្រូបង្រៀន | 6 | 5 |
| **3** | **មត្តេយ្យសិក្សាសហគមន៍** | | |
| | ចំនួនសាលា | 4 | 4 |
| | ចំនួនថ្នាក់ | 4 | 4 |
| | ចំនួនកុមារ | 92 | 99/51 |
| | ចំនួនគ្រូបង្រៀន | 4 | 4 |

iSkysoft

| | | | |
|---|---|---|---|
| **II** | **ផ្នែកអប់រំបឋមសិក្សា** | | |
| **1** | **ផ្នែកបឋមសិក្សារដ្ឋ** | | |
| | ចំនួនកម្រង | 3 | 3 |
| | ចំនួនសាលា | 13 | 13 |
| | ចំនួនបន្ទប់រៀន | 100 | 96 |
| | ចំនួនថ្នាក់រៀន | 141 | 137 |
| | ចំនួនសិស្សសរុប | 4604 | 4592 |
| | ស្រី | 2187 | 2197 |
| | ចំនួនគ្រូបង្រៀនសរុប | 188 | 183 |
| | ស្រី | 141 | 139 |
| **2** | **បឋមសិក្សាឯកជន** | | |

Remove Watermark Now

| | | | |
|---|---|---|---|
| | ចំនួនសាលា | 2 | 2 |
| | ចំនួនបន្ទប់រៀន | 2 | 2 |
| | ចំនួនថ្នាក់រៀន | 2 | 2 |
| | ចំនួនសិស្សសរុប | 105 | 107 |
| | ស្រី | 49 | 49 |
| | ចំនួនគ្រូបង្រៀនសរុប | 19 | 14 |
| | ស្រី | 13 | 12 |

| | | | |
|---|---|---|---|
| **III** | **ផ្នែកអប់រំមធ្យមសិក្សា** | | |
| **1** | **ផ្នែកទុតិយភូមិ** | | |
| | ចំនួនសាលា | 2 | 2 |
| | ចំនួនបន្ទប់រៀន | 54 | 53 |
| | ចំនួនថ្នាក់រៀន | 54 | 53 |
| | ចំនួនសិស្សសរុប | 2353 | 2520 |
| | ស្រី | 1236 | 1332 |
| | ចំនួនគ្រូបង្រៀនសរុប | 141 | 140 |
| | ស្រី | 69 | 71 |
| **2** | **ផ្នែកបឋមភូមិ** | | |
| | ចំនួនសាលា | 5 | 5 |
| | ចំនួនបន្ទប់រៀន | 27 | 26 |
| | ចំនួនថ្នាក់រៀន | 27 | 26 |
| | ចំនួនសិស្សសរុប | 1235 | 1272 |
| | ស្រី | 625 | 659 |
| | ចំនួនគ្រូបង្រៀនសរុប | 87 | 89 |
| | ស្រី | 51 | 53 |

iSkysoft

## ៣.៨.៤. ស្រុក ព្រែកប្រសព្វ

### ១.១-ការអប់រំកុមារតូច

Remove Watermark Now

| ១-មត្តេយ្យសិក្សារដ្ឋ | ឆ្នាំសិក្សា២០១៦-២០១៧ | ឆ្នាំសិក្សា២០១៧-២០១៨ |
|---|---|---|
| ចំនួនសាលា/កន្លែង | 19 | 20 |
| ចំនួនថ្នាក់ | 28 | 30 |
| ចំនួនកុមារ | 889 | 917 |
| ចំនួនគ្រូបង្រៀន | 42 | 42 |
| ២-មត្តេយ្យសិក្សាឯកជន | | |
| ចំនួនសាលា/កន្លែង | 0 | 0 |
| ចំនួនថ្នាក់ | 0 | 0 |
| ចំនួនកុមារ | 0 | 0 |
| ចំនួនគ្រូបង្រៀន | 0 | 0 |
| ៣-មត្តេយ្យសិក្សាសហគមន៍ | | |
| ចំនួនសាលា/កន្លែង | 15 | 16 |
| ចំនួនថ្នាក់ | 15 | 16 |
| ចំនួនកុមារ | 376 | 443 |
| ចំនួនគ្រូបង្រៀន | 15 | 16 |
| ៤-កម្មវិធីអប់រំកុមារតូចតាមផ្ទះ | | |
| ចំនួនភូមិ | 48 | 48 |
| ចំនួនមាតាបិតាបង្គោល | 48 | 48 |
| ចំនួនកុមារ | 1357 | 1436 |
| ចំនួនសមាជិកម្តាយសរុប | 1208 | 1202 |

iSkysoft

## ១.២-ការអប់រំបឋមសិក្សា

| បរិយាយ | | ឆ្នាំសិក្សា ២០១៦-២០១៧ | ឆ្នាំសិក្សា ២០១៧-២០១៨ |
|---|---|---|---|
| ចំនួនកម្រង | | 9 | 9 |
| ចំនួនសាលា | | 45 | 45 |
| ចំនួនបន្ទប់រៀន | | 224 | 226 |
| ចំនួនថ្នាក់រៀន | | 326 | 334 |
| ចំនួនសិស្ស | សរុប | 9586 | 9589 |
| | ស្រី | 4645 | 4598 |
| ចំនួនគ្រូបង្រៀនសរុប | | 329 | 342 |

| | | |
|---|---|---|
| ស្រី | 220 | 226 |

## ១.៣-ការអប់រំមធ្យមសិក្សា

| បរិយាយ | ឆ្នាំសិក្សា ២០១៦-២០១៧ | ឆ្នាំសិក្សា ២០១៧-២០១៨ |
|---|---|---|
| ចំនួនវិទ្យាល័យ | 2 | 2 |
| ចំនួនបន្ទប់រៀន | 46 | 45 |
| ចំនួនថ្នាក់រៀន | 46 | 45 |
| ចំនួនសិស្ស សរុប | 1792 | 1868 |
| ស្រី | 922 | 1027 |
| ចំនួនគ្រូបង្រៀន សរុប | 130 | 122 |
| ស្រី | 58 | 55 |
| ចំនួនអនុវិទ្យាល័យ | 7 | 7 |
| ចំនួនបន្ទប់រៀន | 53 | 39 |
| ចំនួនបន្ទប់រៀន | 53 | 55 |
| ចំនួនសិស្ស សរុប | 1746 | 1807 |
| ស្រី | 910 | 950 |
| ចំនួនគ្រូបង្រៀន សរុប | 119 | 115 |
| ស្រី | 50 | 49 |

## ៣.៨.៥. ស្រុក សំបូរ

### ១.១-ការអប់រំកុមារតូច

| ១-មត្តេយ្យសិក្សារដ្ឋ | ឆ្នាំសិក្សា២០១៦-២០១៧ | ឆ្នាំសិក្សា២០១៧-២០១៨ |
|---|---|---|
| ចំនួនសាលា/កន្លែង | 14 | 15 |
| ចំនួនថ្នាក់ | 17 | 18 |
| ចំនួនកុមារ | 388 | 424 |
| ចំនួនគ្រូបង្រៀន | 9 | 9 |
| ២-មត្តេយ្យសិក្សាឯកជន | | |
| ចំនួនសាលា/កន្លែង | 0 | 0 |
| ចំនួនថ្នាក់ | 0 | 0 |
| ចំនួនកុមារ | 0 | 0 |

Remove Watermark Now

| | | |
|---|---|---|
| ចំនួនគ្រូបង្រៀន | 0 | 0 |
| **៣-មត្តេយ្យសិក្សាសហគមន៍** | | |
| ចំនួនសាលា/កន្លែង | 26 | 26 |
| ចំនួនថ្នាក់ | 26 | 26 |
| ចំនួនកុមារ | 401 | 563 |
| ចំនួនគ្រូបង្រៀន | 26 | 26 |
| **៤-កម្មវិធីអប់រំកុមារតូចតាមផ្ទះ** | | |
| ចំនួនភូមិ | 41 | 33 |
| ចំនួនមាតាបិតាបង្គោល | 42 | 34 |
| ចំនួនកុមារ | 1,398 | 917 |
| ចំនួនសមាជិកម្តាយសរុប | 1,021 | 901 |

### ១.២-ការអប់រំបឋមសិក្សា

| បរិយាយ | ឆ្នាំសិក្សា ២០១៦-២០១៧ | ឆ្នាំសិក្សា ២០១៧-២០១៨ |
|---|---|---|
| ចំនួនកម្រង | 11 | 11 |
| ចំនួនសាលា | 56 | 56 |
| ចំនួនបន្ទប់រៀន | 316 | 323 |
| ចំនួនថ្នាក់រៀន | 438 | 439 |
| ចំនួនសិស្ស សរុប | 11,774 | 11,775 |
| ស្រី | 5,742 | 5,747 |
| ចំនួនគ្រូបង្រៀន សរុប | 326 | 280 |
| ស្រី | 172 | 164 |

iSkysoft

### ១.៣-ការអប់រំមធ្យមសិក្សា

| បរិយាយ | ឆ្នាំសិក្សា ២០១៦-២០១៧ | ឆ្នាំសិក្សា ២០១៧-២០១៨ |
|---|---|---|
| ចំនួនវិទ្យាល័យ | 2 | 2 |
| ចំនួនបន្ទប់រៀន | 30 | 30 |
| ចំនួនថ្នាក់រៀន | 33 | 33 |
| ចំនួនសិស្ស សរុប | 1,515 | 1,626 |
| ស្រី | 822 | 852 |
| ចំនួនគ្រូបង្រៀន សរុប | 82 | 71 |

| | | |
|---|---|---|
| ស្រី | 26 | 25 |
| ចំនួនអនុវិទ្យាល័យ | 8 | 8 |
| ចំនួនបន្ទប់រៀន | 30 | 26 |
| ចំនួនបន្ទប់រៀន | 27 | 27 |
| ចំនួនសិស្ស សរុប | 1,029 | 1,147 |
| ស្រី | 603 | 658 |
| ចំនួនគ្រូបង្រៀន សរុប | 70 | 61 |
| ស្រី | 30 | 27 |

### ៣.៨.៦. ស្រុក ស្នួល

**I .ការងារផ្នែកអប់រំកុមារតូច**

-ក្នុងឆ្នាំសិក្សា២០១៧ នេះចំពោះមតេយ្យសិក្សារដ្ឋកើនបាន ចំនួន ០៩ កន្លែង ៩ថ្នាក់ ។

-ចំពោះមតេយ្យសហគមន៍ និងអប់រំកុមារតូចតាមផ្ទះនៅថេរដដែល (មិនប្រែប្រួល) ។

**II .ការងារផ្នែកអប់រំបឋមសិក្សា**

-អត្រាពិតចូលរៀនថ្មី 85,23 % ស្រី 87,61%

-អត្រាចូលរៀនថ្មី 120,85 % ស្រី 121,19 %

-អត្រាពិតនៃការសិក្សា 96,55 % ស្រី 97,79 %

-អត្រារួមនៃការសិក្សា 121,07% ស្រី 117,88 %

-អត្រាឡើងថ្នាក់ 85,16% ស្រី 87,20%

-អត្រាត្រួតថ្នាក់ 9,94% ស្រី 8,55%

-អត្រាបោះបង់ 4,90% ស្រី 4,25%

-អត្រាឆ្លងភូមិសិក្សា 86,63% ស្រី 87,85 %

-អត្រាបញ្ចប់ការសិក្សា 50,85% ស្រី 66,51 %

**III .ការងារផ្នែកមធ្យមសិក្សា**

-សិស្សប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សា ចំនួន 352 នាក់ ស្រី 191 នាក់ ស្មើ 98,05%

-សិស្សប្រឡងជាប់មធ្យមសិក្សាទុតិយភូមិ 62 នាក់ ស្រី 30 នាក់ស្មើ 49,20 %

-សិស្សជនជាតិដើមភាគតិច ថ្នាក់ទី១១ វិទ្យាល័យហ៊ុន សែន ស្នួល បានទទួលអាហារូបករណ៍ ចំនួន 18 នាក់ ស្រី 13 នាក់

-សិស្សអនុវិទ្យាល័យ4 កន្លែងមានចំនួន 120 នាក់ បានទទួលអាហារូបករណ៍សិស្សក្រីក្រ ។

-សាលាមួយចំនួនបានរៀបចំបរិស្ថាន បានស្អាតសមរម្យ ។

-សហគមន៍សប្បុរសជន អង្គការនានា បានចូលរួមកសាង និងអភិវឌ្ឍន៍សាលារៀនបានច្រើន កន្លែង ។

**IV .ការងារផ្នែកអប់រំក្រៅប្រព័ន្ធ**

-បើកថ្នាក់អក្ខរកម្មបានចំនួន ០៥ ថ្នាក់ សិស្សសរុប ១០៧នាក់ ស្រី ៦៦នាក់

-បើកមជ្ឈមណ្ឌលសហគមន៍បាន ០១កន្លែង (ឃុំស្វាយជ្រះ) សិស្សសរុបចំនួន ២២នាក់ ស្រី ២១នាក់

Remove Watermark Now

បានបញ្ចប់ចំនួន ១២នាក់ ស្រី ១២នាក់ ធ្លាក់មធ្យមភាគ ៩នាក់ ស្រី៩ បោះបង់ ១នាក់ ស្រី ០០នាក់ ។

-បើកថ្នាក់កម្មវិធីចូលរៀនឡើងវិញបានចំនួន ០៦ថ្នាក់ សិស្សសរុបចំនួន ១០០នាក់ ស្រី ៥៤នាក់ បានបញ្ចប់ និងរៀនបន្តចំនួន ៨៥នាក់ ស្រី ៣១នាក់ ។

## V .ការងារផ្នែកគណនេយ្យ

-មានសម្ភារដំណើរការរដ្ឋបាល

-ការចុះឈ្មោះចូលរៀន និងអត្រាគងវង់មានការកើនឡើង

-មានការចូលរួមពីសហគមន៍ និងអ្នកពាក់ព័ន្ធ

-សាលារៀនលម្អបរិស្ថាន ស្របតាមការអនុវត្តន៍កម្មវិធីសាលាកុមារមេត្រី

-គ្រូបង្រៀនមានសម្ភារឧទ្ទេសប្រើប្រាស់ក្នុងការបង្រៀនកើនឡើង

## VI .ការងារក្រុមប្រឹក្សាកុមារ

-សាលារៀនបង្កើតបានក្រុមប្រឹក្សាយុវជន និងកុមារគ្រប់សាលា

-ដំណើរការតាមសាលារៀនមានវិន័យល្អ

-ចេះជួយទុកធុរៈគ្នានៅពេលមានគ្រោះថ្នាក់

-ចេះជួយបង្រៀនគ្នា (សិស្សយឺតរៀន)

-សាលារៀនមានបរិស្ថានល្អ (ក្នុងថ្នាក់ស្អាត)

-សិស្សយល់ដឹងច្រើន និងមានវិន័យល្អ

## VII .ការងារផ្នែកកីឡា

-សាលាមានការរីកចម្រើនផ្នែកវិស័យកីឡា កើនឡើង

-ទទួលបានលទ្ធផល បានទៅប្រកួតថ្នាក់ខេត្ត

-បានប្រឡងប្រណាំងតាមសាលាមានការកើនឡើង

iSkysoft

## ២.៩. ការងារដៃគូអភិវឌ្ឍ

**១-អង្គការ** ChildFund Cambodia

**លទ្ធផលអនុវត្តបាន៖** រៀបចំសិក្សាសាលា និងវគ្គបណ្ដុះបណ្ដាលរយៈពេល ៣ថ្ងៃ នៅស្រុកឆ្លូង ស្ដីពីការគ្រប់គ្រង និងដឹកនាំ ដែលមានអ្នកចូលរួមចំនួន១១២នាក់/២នាក់ ។

- DTMT 74 នាក់/៤១នាក់ បានទទួលវគ្គបណ្ដុះបណ្ដាលពង្រឹងសមត្ថភាពទៅលើការប្រើប្រាស់ឧបករណ៍ស្តង់ដារដឹកនាំ។
- អ្នកចូលរួម ២៤នាក់/៦នាក់បានចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពីជំនាញនៃការត្រួតពិនិត្យដែលសម្របសម្រួលដោយ DTMT នៅស្រុកឆ្លូង។
- ជនបង្គោលចំនួន ៦១នាក់/២៤នាក់ មកពីស្រុក ឆ្លូង និងស្រុក ចិត្របុរី បានចូលរួមទស្សនៈកិច្ចសិក្សាដើម្បីរៀនសូត្រពីគម្រោងងាយស្រួលរៀន នៅខេត្តស្វាយរៀង។
- សមាជិក DTMT និងPWG រួមទាំងបុគ្គលិកគម្រោងបានរៀបចំការប្រជុំបច្ចេកទេសតាមកម្រង ចំនួន ៨០ប្រជុំ ដោយនៅក្នុងនោះ ៨កម្រងនៅក្នុងស្រុកឆ្លូងដោយផ្ដោតទៅលើ ពង្រឹងបច្ចេកទេសការបង្រៀន និងការរៀន។
- គណៈកម្មការទ្រទ្រង់សាលា ៥៣នាក់/២០នាក់បានចូលរួមសិក្ខាសាលាឆ្លុះបញ្ចាំងគម្រោងប្រចាំឆ្នាំ

នៅ ស្រុកឆ្លូង។

- ប្រជុំប្រចាំខែក្រុមបច្ចេកទេសបានចំនួន ៣ដង ដែលផ្តោតទៅលើការបង្រៀន និងរៀនដែលរៀបចំដោយ DTMT ទៅលោកគ្រូ អ្នកគ្រូ ទាំងអស់នៅសាលាគោលដៅ និងសាលឧបសម្ព័ន្ធនៅក្រោមការគ្រប់គ្រងរបស់កម្រងគោលដៅ ដែលផ្តោតការតាមដានទៅលើគំរូនៃការបង្រៀនសម្រាប់ថ្នាក់ដំបូងនៅក្នុងស្រុកចិត្របុរី។
- ដឹកនាំវេទិកាពិគ្រោះយោបល់នៅសហគមន៍ ចំនួន៩ដង ក្នុងគោលបំណងជំរុញលើកទឹកចិត្តដល់មាតាបិតា និង សិស្សានុសិស្សឱ្យលើកឡើងពីបញ្ហាប្រឈម និងសំណើដែលទាក់ទងនឹងគុណភាពនៃការបង្រៀន និងរៀន បញ្ហាលើកិច្ចការពារកុមារ អត្រាបោះបង់ការសិក្សា ការចុះឈ្មោះចូលរៀនរបស់កុមារ និងការងារអភិវឌ្ឍន៍សាលារៀន នៅសាលាគោលដៅក្នុងស្រុកចិត្របុរី។
- ៩សកម្មភាពចំបងៗ ដែលមានការធ្វើថ្នាក់បង្ហាញ ការដឹកនាំក្រុមប្រជុំបច្ចេកទេស សិក្ខាសាលាឆ្លុះបញ្ចាំងប្រចាំឆ្នាំ JTWG ដែលមានការប្រជុំជាមួយអ្នកពាក់ព័ន្ធ។
- ចង្កៀងសូឡាចំនួន ១,៩១៧ចង្កៀងគឺបានផ្តល់ជូនទៅសិស្សក្រីក្រចំនួន១,៩១៧នាក់ នៅក្នុងស្រុកចិត្របុរី។
- ប្រអប់សង្គ្រោះបន្ទាន់ចំនួន៣៥ប្រអប់ ត្រូវបានផ្តល់ឱ្យសាលាបឋមសិក្សាចំនួន១៤ ក្នុងស្រុកចិត្របុរី។
- ឯកសណ្ឋានសិស្សចំនួន ៨០កំភ្លេតត្រូវបានផ្តល់ឱ្យដល់សិស្សក្រីក្រចំនួន៨០នាក់ នៅសាលាបឋមសិក្សាមួយក្នុងស្រុកឆ្លូង។
- បានផ្តល់ជូនសៀវភៅសម្រាប់សាលាដែលមានបណ្ណាល័យដល់សាលាបឋមសិក្សាចំនួន១១ ក្នុងស្រុកចិត្របុរី និងស្រុកឆ្លូង ចំនួន៥,១៥០ក្បាល។
- បានផ្តល់ស្ថានីលាងដៃចំនួន៤ ទៅដល់សាលាបឋមសិក្សា៤ក្នុងស្រុកចិត្របុរី។
- បានផ្តល់បង្គន់អនាម័យចំនួន២ ដែលមាន ៨បន្ទប់ ក្នុងស្រុកចិត្របុរី។
- បានផ្តល់អណ្តូងសូឡា ដល់សាលាបឋមសិក្សាចំនួន២ នៅស្រុកឆ្លូង ។
- បានគាំទ្រអង្គការក្នុងស្រុកចំនួនពីរគម្រោង គឺអង្គការខេប (KAPE)ក្នុងស្រុកឆ្លូង និងអង្គការ KAFDOC ក្នុងស្រុក ចិត្របុរី។
- បានផ្តល់ស្ថានីលាងដៃចំនួន២ ទៅដល់សាលាបឋមសិក្សាចំរើន និងមួយរយប្រាំក្នុងស្រុកចិត្របុរី។
- បានផ្តល់អណ្តូងសូឡា ដល់សាលាបឋមសិក្សាចំនួន១ នៅសាលាបឋមសិក្សាមួយរយប្រាំ ស្រុកចិត្របុរី។
- បានផ្តល់សាលា១ខ្នង ចំនួន៦បន្ទប់ សម្រាប់សាលាបឋមសិក្សាស្រែដូង ស្រុកចិត្របុរី។
- បានផ្តល់អគារបណ្ណាល័យ១ខ្នង ចំនួន១បន្ទប់សម្រាប់សាលាបឋមសិក្សាកន្ទួត ស្រុកចិត្របុរី។
- បានផ្តល់សម្ភារៈសម្រាប់រៀបចំសួនជីវចម្រុះចំនួន៤សាលាគោលដៅ(កន្ទួត តាលុស ចំរើន និងមួយរយប្រាំ) ស្រុកចិត្របុរី។
- បានផ្តល់វគ្គបណ្តុះបណ្តាល រយៈពេល១ថ្ងៃស្តីពីការប្រើប្រាស់សម្ភារៈឧបទេស(សម្ភារៈពង្រឹងអំណានថ្នាក់ដំបូង)សម្រាប់ស្រុកចិត្របុរី។
- បានផ្តល់សម្ភារៈឧបទេស(សម្ភារៈពង្រឹងអំណានថ្នាក់ដំបូង) ចំនួន២០ ឈុតដល់សាលាគោលដៅក្នុងស្រុកចិត្របុរី។

Remove Watermark Now
iSkysoft

Remove Watermark Now

- បានផ្តល់ធុងចម្រោះទឹកស្អាតដល់សាលាគោលដៅក្នុងស្រុកចិត្របុរីចំនួន៩ធុង។
- បានផ្តល់វគ្គបណ្តុះបណ្តាល រយៈពេល៤ថ្ងៃស្តីពីការគ្រប់គ្រងបណ្ណាល័យទៅដល់សាលាគោលដៅ (កន្ទួត) ចំរើន មួយរយប្រាំ ស្រែដូង តាលុស)ចំនួន១លើក។
- គណៈកម្មការ នាយកសាលា អាជ្ញាធរ វិស្វករ ការិយាល័យអប់រំ មន្ទីរអប់រំ និងមន្ត្រីគម្រោងបានចុះមើលការសាងសង់អគារបណ្ណាល័យនៅសាលាបឋមសិក្សាកន្ទួត និងអគារសិក្សានៅសាលាបឋមសិក្សាស្រែដូងជាប្រចាំ។
- បានប្រជុំប្រចាំខែជាមួយគណៈកម្មការ និងអ្នកពាក់ព័ន្ធពីការងារសាងសង់អគារបណ្ណាល័យ និងអគារសិក្សា ចំនួន ៣លើក។
- បានប្រជុំរៀបចំថ្នាក់រៀនជាមួយលោកគ្រូអ្នកគ្រូ SSC បានចំនួន៣លើក។
- ចង្កៀងសូឡាចំនួន១,៨១៧ចង្កៀងគឺបានផ្តល់ជូនទៅសិស្សក្រីក្រចំនួន ១,៨១៧នាក់នៅក្នុងស្រុកចិត្របុរី។
- ប្រអប់សង្គ្រោះបន្ទាន់ចំនួន៣៥ ប្រអប់ត្រូវបានផ្តល់អោយសាលាបឋមសិក្សាចំនួន១៩ ក្នុងស្រុកចិត្របុរី។
- ឯកសណ្ឋានសិស្សចំនួន៨០កំប្លេត្រូវបានផ្តល់អោយដល់សិស្សក្រីក្រចំនួន៨០នាក់ នៅសាលាបឋមសិក្សាមួយក្នុងស្រុកឆ្លូង។
- បានផ្តល់ជូនសៀវភៅសម្រាប់សាលាដែលមានបណ្ណាល័យដល់សាលាបឋមសិក្សាចំនួន១១ ក្នុងស្រុកចិត្របុរី និងស្រុកឆ្លូង ចំនួន៥,១៥០ក្បាល។
- បានផ្តល់វគ្គបំប៉នដល់បណ្ណារក្ស នាយកសាលា និងមន្ត្រីអ.យ.កស្រុក និងខេត្តចំនួន១លើក ស្តីពីការគ្រប់គ្រងបណ្ណាល័យ។ អ្នកចូលរួម២៥នាក់ (ស្រី១២នាក់)។
- បានផ្តល់វគ្គបំប៉នដល់លោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ដំបូង (ទី១-៣)នាយកសាលា និងមន្ត្រីអ.យ.កស្រុកនិងខេត្តចំនួន១លើក ស្តីពីវិធីសាស្ត្របង្រៀនថ្នាក់ដំបូង។ អ្នកចូលរួម៣០នាក់ (ស្រី១៥នាក់)។
- បានផ្តល់វគ្គបំប៉នបំណិនជីវិតដល់លោកគ្រូ អ្នកគ្រូ នាយកសាលា និងមន្ត្រីអ.យ.កស្រុក និងខេត្តចំនួន១លើក ស្តីពីវិធីបច្ចេកទេសកសិកម្ម (ដាំបន្លែ និងចិញ្ចឹមត្រី)។ អ្នកចូលរួម១៧នាក់ (ស្រី៥នាក់)។
- បាននិងកំពុងបន្តសាងសង់អគារសិក្សាមួយខ្នង (៦បន្ទប់)នៅសាលាបឋមសិក្សាស្រែដូង ឃុំថ្មអណ្តើក និងបណ្ណាល័យទំនើបមួយកន្លែងនៅសាលាបឋមសិក្សាកន្ទួត ឃុំកន្ទួត ស្រុកចិត្របុរី។
- បានគាំទ្រគណៈកម្មការត្រួតពិនិត្យគុណភាព ចុះត្រួតពិនិត្យការសាងសង់អគារ និងបណ្ណាល័យសិក្សាខាងលើជាប្រចាំ។

បានគាំទ្រអង្គការក្នុងស្រុកចំនួនពីរគម្រោង គឺអង្គការខេប (KAPE) ក្នុងស្រុកឆ្លូង និង អង្គការ KAFDOC ក្នុងស្រុក ចិត្របុរី។

**២-អង្គការ** KAFDOC

**លទ្ធផលអនុវត្តបានៈ**

**១- ផ្នែកអប់រំកុមារតូចៈ**

-បានសហការជាមួយមន្ទីរអប់រំខេត្ត ផ្នែកអប់រំកុមារតូចចុះស្រាវជ្រាវរកតម្រូវការរបស់សាលាមត្តេយ្យ ទាំង៥នៅក្នុងស្រុកចិត្របុរី។

Remove Watermark Now

-សិក្ខាសាលាថ្នាក់ខេត្ត សម្របសម្រួលដោយការិយាល័យអប់រំកុមារតូចនៃមន្ទីរអប់រំខេត្ត៖ អ្នកចូលរួម ១៩នាក់ស្រី១១នាក់ នៃសាលាគោលដៅទាំង៥ ដើម្បីធ្វើផែនការអនុវត្តគម្រោង។

-បានសហការជាមួយការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំខេត្ត និងការិយាល័យអប់រំស្រុកចិត្របុរី ដើម្បីបំប៉នដល់គ្រូមត្តេយ្យ និងនាយកសាលាទាំង៥ ស្តីពី ការប្រើប្រាស់ឧបករណ៍ស្តង់ដារអប្បបរមា និងការរៀបចំថ្នាក់រៀន។

-សាលាមត្តេយ្យសិក្សាចំនួន២ ត្រូវបានកែលម្អ ស្តង់ដារបន្ទប់រៀន។

**២- ផ្នែកអប់រំបឋមសិក្សា៖**

១-បានបំប៉នដល់គ្រូបង្រៀន និងយកសាលាគោលដៅទាំង១៩ សាលាក្នុងស្រុក ចិត្របុរី និងស្រុកសំបូរ និង DTMT បានចំនួន ៩វគ្គ ស្តីពី ការរៀបចំកិច្ចតែងការបង្រៀន, ការប្រើប្រាស់សម្ភារៈពង្រឹងអំណាន និងគណិតវិទ្យា, វិធីសាស្រ្តបង្រៀនស្តង់ដារអំណានថ្នាក់ដំបូង(ថ្នាក់ទី១-៣), និង ការប្រើប្រាស់ឧបករណ៍វាយតម្លៃ ការសិក្សា របស់សិស្សតាមដំណាក់កាលអំណាន ដោយសហការសម្របសម្រួល វគ្គដោយមន្ទីរអប់រំខេត្ត និងការិយាល័យអប់រំស្រុក សាលាគរុកោសល្យ និងវិក្រិតការខេត្តក្រចេះ និងអង្គការ KAPE។

២-បានបំប៉នដល់នាយក នាយករងសាលាគោលដៅចំនួន៧ និង DTMT ស្តីពីការគ្រប់គ្រងសាលារៀន និងភាពជាអ្នកដឹកនាំ បានចំនួន១វគ្គ។

៣-បានបំប៉ននាយក នាយករងសាលា គណៈកម្មការទ្រទ្រង់សាលា អាជ្ញាធរមូលដ្ឋាន ស្តីពីធ្វើផែនការ អភិវឌ្ឍន៍សាលារៀន បានចំនួន១វគ្គ ដែលសម្របសម្រួលដោយ ការិយាល័យអប់រំស្រុក មន្ទីរអប់រំខេត្ត និងអង្គការ ឆាលហ្វាន កម្ពុជា។

iSkysoft

៤-បានបំប៉ន នាយកសាលារៀន គណៈកម្មការទ្រទ្រង់សាលា ក្រុមប្រឹក្សាកុមារ គ្រូទីប្រឹក្សាកុមារី គ.ក.ន.ក ស្តីពី ជំនាញប្រឹក្សាយោបល់ ដល់កុមារ និងគ្រួសារប្រឈមការបោះបង់ការសិក្សា បាន ១វគ្គ ដោយ សហការសម្របសម្រួលដោយ ការិយាល័យអប់រំស្រុក និង មន្ទីរអប់រំខេត្ត។ អ្នកចូលរួម ៧៩នាក់ស្រី៦៨នាក់។

៥-បានបំប៉ន ដល់បណ្ណារក្ស និងនាយកសាលាគោលដៅទាំង៧នៃស្រុកចិត្របុរី ស្តីពី ការគ្រប់គ្រងបណ្ណាល័យ បានចំនួន២វគ្គ ដោយសម្របសម្រួលដោយ អង្គការ ឆាលហ្វាន កម្ពុជា និងក្រសួងអប់រំ។

៦-បានបំប៉នគ្រូបណ្ណារក្ស និងគ្រូបង្វឹកអំណាន នៃសាលាគោលដៅទាំង៧នៃស្រុកចិត្របុរី ស្តីពី ការប្រើប្រាស់ឧបករណ៍តេស្តស្តង់ដារអំណានតាមដំណាក់កាល, ការប្រើប្រាស់សម្ភារៈពង្រឹងអំណាន, និងវិធីសាស្រ្តបង្រៀន អំណានថ្នាក់ដំបូង។

៧-បានបំប៉នដល់នាយកសាលា គណៈកម្មការទ្រទ្រង់សាលា គ .ក.ន.ក.ឃុំ ប៉ុស្តិ៍រដ្ឋបាលឃុំ ស្តីពី ការធ្វើ ផែនទីសិក្សា និងផែនទីខ្នងផ្ទះ។

៨-បានគាំទ្រដល់ដំណើរការធ្វើផែនទីសិក្សា និងផែនទីខ្នងផ្ទះដល់សាលាគោលដៅទាំង៧នៃស្រុកចិត្របុរី

៩-បានគាំទ្រដល់ដំណើរការធ្វើផែនការកែលម្អសាលារៀន ដល់សាលាគោលដៅទាំង៧នៃស្រុកចិត្របុរី។

១០-បានគាំទ្រដល់ដំណើរការធ្វើយុទ្ធនាការប្រមូលកុមារចូលរៀននៅដើមឆ្នាំសិក្សា ដល់សាលា

Remove Watermark Now

គោលដៅ ទាំង៧នៃស្រុកចិត្របុរី។

១១-បានផ្តល់ហិបសម្ភារ:ពង្រឹងអំណានចំនួន ៩៥ហិប សម្រាប់សាលាចំនួន១០ក្នុង ស្រុកចិត្របុរី និង ស្រុកសំបូរ។

១២-បានផ្តល់ឧបករណ៍/ឯកសារតេស្តសមត្ថភាពអំណាន ថ្នាក់ទី១-៣ចំនួន ៣៥ថ្នាក់ សម្រាប់សាលាគោល ដៅចំនួន៧នៃស្រុកចិត្របុរី

១៣-បានបើកគណនេយ្យធនាគារសម្រាប់សាលាគោលដៅទាំង៧(ជាពិសេសសម្រាប់គណ:កម្មការទ្រទ្រង់សាលារៀន) នៃស្រុកចិត្របុរី ដើម្បីប្រើប្រាស់ថវិកាគម្រោងក្នុងការអភិវឌ្ឍសាលារៀន។

១៤-បានជ្រើសរើស និងគាំទ្រគ្រូបង្វឹកអំណានចំនួន៧នាក់ស្រី៦នាក់សម្រាប់សាលាគោលដៅទាំង៧ក្នុងស្រុកចិត្របុរី ដើម្បីជួយពង្រឹងអំណានដល់កុមារដែលមានតម្រូវការរៀនបន្ថែម។

១៥-បានចូលរួមគាំទ្រការប្រជុំក្រុមបច្ចេកទេស និងថ្នាក់និទស្សន៍ ចំនួន៦ដងសម្រាប់ផកម្រងសាលារៀន ក្នុងស្រុកចិត្របុរី និង ស្រុកសំបូរ។

១៦-បានរៀបចំ និងសហការរៀបចំទិវាសិទ្ធិកុមារចំនួន៥កន្លែង មានអ្នកចូលរួមចំនួន១២៣៦នាក់ ស្រី ៦៨៣នាក់។

១៧-បានសហការ និងរៀបចំវេទិកាសាធារណ:(កិច្ចសន្ទនា) ជាមួយមន្ទីរអប់រំខេត្ត ការិយាល័យអប់រំស្រុក និង ក្រុមប្រឹក្សាឃុំ ចំនួន១២វេទិកា ស្តីពី ប្រសិទ្ធភាព នៃការបង្រៀន និងរៀន, សុខភាព សុវត្ថិភាព និង ការ ការពារកុមារ, និងការចូលរួមរបស់កុមារ គ្រួសារ និង សហគមន៍។ អ្នកចូលរួមចំនួន ១៦៩៩នាក់ ស្រី ៩៥៨ នាក់

iSkysoft

១៨-សហការជាមួយមន្ទីរអប់រំខេត្ត និងការិយាល័យអប់រំស្រុកគោលដៅ ចុះតាមដាន និងវាយតម្លៃលទ្ធផលការងារ សាលារៀន និងថ្នាក់រៀនក្នុងកម្មវិធីសាលាកុមារមេត្រី បានចំនួន២ដង សម្រាប់សាលាគោលដៅចំនួន១៣។

១៩-គាំទ្រ និងសម្របសម្រួលការប្រជុំត្រីមាសរបស់គណ:កម្មការទ្រទ្រង់សាលាបានចំនួន៤ដង, ប្រជុំមាតាបិតា សិស្សបានចំនួន២ដង គ្រប់សាលាគោលដៅ, បង្កើតក្រុមបណ្តាញការពារសុវត្ថិភាព កុមារថ្នាក់ឃុំចំនួន៨, លើកកម្ពស់កុមារឲ្យបានចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ។

២០-សហការជាមួយវិទ្យុសំឡេងស្ត្រីសហគមន៍ (FM89.50)ខេត្តក្រចេះដើម្បីធ្វើការ ចុះផ្សព្វផ្សាយបង្កើន ចំណេះដឹង ដល់សហគមន៍ កុមារ ស្តីពី សិទ្ធិកុមារ ការចុះឈ្មោះចូលរៀន អំពើហិង្សា ការចុះសំបុត្រកំណើត និង ការជួយបង្រៀនកុមារនៅផ្ទះពីមាតាបិតា បានចំនួន ២ដង ក្នុងភូមិគោលដៅចំនួន១១ ក្នុងស្រុកចិត្របុរី។ មានអ្នកចូលរួមចំនួន៨៧៥នាក់ ស្រី ៥៩៥នាក់។

២១-បានរៀបចំ និងជួសជុលកែលម្អកន្លែងលេងកម្សាន្តរបស់កុមារក្នុងសាលារៀនគោលដៅទាំង ១១ (សួនកុមារ) និងសួនជីវ:ចម្រុះសម្រាប់សាលារៀន។

២២-ផ្តល់កញ្ចប់ថវិកាសម្រាប់ការអភិវឌ្ឍន៍សាលារៀន និងការបង្រៀនចំនួន ៥៥០០ដុល្លាអាមេរិក (មួយសាលា៥០០ ដុល្លារអាមេរិក) សម្រាប់១១សាលាគោលដៅក្នុងស្រុកចិត្របុរី។

២៣-បានចូលរួមគាំទ្រ ការប្រជុំក្រុមបច្ចេកទេសចម្រុះគាំទ្រវិស័យអប់រំខេត្ត។

**៣-អង្គការ** KAPE

Remove Watermark Now

តំបន់គោលដៅ៖ មានបួនស្រុក គឺ ស្រុកស្នួល សំបូរ ចិត្របុរី និង ស្រុកឆ្លូង។ ឆ្នាំសិក្សា ២០១៦-២០១៧ នេះអង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា (KAPE) បានសហការជាដៃគូ និង ឧបត្ថម្ភដល់វិស័យអប់រំនៅក្នុងខេត្តក្រចេះ មានចំនួន០២គម្រោង គឺគម្រោង អប់រំកុមារ (EAC) និងគម្រោង ភាពជាអ្នកដឹកនាំ និងគ្រប់គ្រងសាលារៀន (SML) ដែលទទួលបានលទ្ធផលដូចខាងក្រោម៖

ផ្នែកបណ្តុះបណ្តាល៖

១-បានបើកវគ្គបំប៉ន ស្តីពី ការពង្រឹងសមត្ថភាពគ្រូកុមារមេត្រី សិក្ខាកាមចូលរួមចំនួន ៩១នាក់ស្រី៦៣នាក់ រយៈពេល ០៣ថ្ងៃ នៅសាលាបឋមសិក្សាភូមិកណ្តាល។

២-បើកវគ្គបំប៉នស្តីពី ការគ្រប់គ្រង និងប្រើប្រាស់បណ្ណាល័យ ដល់បណ្ណារក្ស ដែលមានអ្នកចូលរួមចំនួន ៩០នាក់ ស្រី២៧នាក់ រយៈពេល០១ថ្ងៃ នៅសាលាបឋមសិក្សាឆ្លូង។

៣-បើកវគ្គបំប៉នស្តីពីតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សា រយៈពេល០១ថ្ងៃ មានអ្នកចូលរួមចំនួន ៥៨នាក់ ស្រី២២នាក់។

៤-បើវគ្គបំប៉នស្តីពីតួនាទីនិងភារកិច្ចរបស់គណៈកម្មការទ្រទ្រង់សាលារយៈពេល០១ថ្ងៃ មានអ្នកចូលរួមចំនួន៥៧នាក់ស្រី២៤នាក់ នៅការិយាល័យ អយក ស្រុកឆ្លូង។

៥-បើកវគ្គសិក្ខាសាលាឆ្លុះបញ្ចាំងពី ភាពជាអ្នកដឹកនាំ និងគ្រប់គ្រងសាលារៀនចំនួន ០៣ថ្ងៃ មានអ្នកចូលរួមចំនួន ២៦ នាក់ ស្រី ០៩នាក់។

ផ្នែកសាងសង់៖

១-បានកសាងបង្គន់ចំនួន ០៤កន្លែង នៅក្នុងស្រុកស្នួល និងចិត្របុរី។

២-បានសាងសង់សាលាឆ្លងកាត់ចំនួន០២ខ្នង ស្មើនិង ០៦បន្ទប់ នៅក្នុងស្រុកស្នួល និងចិត្របុរី។

iskysoft

ផ្នែកសម្ភារៈ

៣-បានផ្តល់សម្ភារៈសិក្សាសម្រាប់កុមារជួយកុមារជូនដល់សាលាចំនួន ០៩កេះ ស្រុកចំនួន០៣ដែលសាលានីមួយៗទទួលបានចំនួន០២កេះ ស្រុកស្នួល ចិត្របុរី និងសំបូរ។

ផ្នែកបំណិនជីវិត

៤-បានផ្តល់ការគាំទ្រផ្នែកបំណិនអាជីពងាយមួយចំនួនដល់សាលាក្នុងស្រុកចំនួន ០៣ រួមមាន៖

១. បំណិនជីវិតកាត់ដេរ មានសិស្សចូលរួមសរុបចំនួន ៣៧នាក់ ស្រី ២៧នាក់។

២. បំណិនជីវិតដាំស្ល មានសិស្សចូលរួមសរុបចំនួន ៦៣នាក់ ស្រី៥៤នាក់។

៣. បំណិនជីវិតដាំបន្លែ មានសិស្សចូលរួមសរុបចំនួន ៥២នាក់ ស្រី២២នាក់។

ផ្នែកអាហារូបករណ៍

៥-បានផ្តល់អាហារូបករណ៍ដល់គរុសិស្សដែលកំពុងសិក្សានៅសាលាគរុកោសល្យចំនួន ០៤នាក់ ស្រី០៣នាក់។

៦-បានផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រសាលាចំនួន ០៩សាលា មានសិស្សសរុប ៤០៤នាក់ ស្រី ២២១នាក់។

ផ្នែកកម្មវិធីសាលាកុមារមេត្រី

១-បានផ្តល់ការរៀបចំ និងកែលម្អថ្នាក់កុមារមេត្រីចំនួន ៦៦បន្ទប់ នៅក្នុងសាលាគោលដៅក្នុងស្រុកទាំង០៤ នៅក្នុងខេត្តក្រចេះ (ឆ្លូង ស្នួល សំបូរ និងចិត្របុរី)។

ការលំបាក/ បញ្ហាប្រឈម៖

២-គ្រូបង្រៀនមួយចំនួនតូចមិនបានអោយតម្លៃលើការប្រជុំបច្ចេកទេស

៣-គ្រូបង្រៀនមួយចំនួនតូចមិនបានយកចិត្តទុកដាក់ក្នុងការផលិតសម្ភារឧបទេស

៤-ការអនុវត្តសកម្មភាពនៅក្នុងសាលាគោលដៅដែលគម្រោងបានគាំទ្រ ពុំទាន់បានល្អប្រសើរ

## ៤-អង្គការ OMF

### ១. កម្មវិធីអប់រំផ្នែកបឋមសិក្សា

-បានឧបត្ថម្ភប្រាក់បៀវត្សដល់គ្រូបង្រៀនផ្នែកបឋមសិក្សា ៧នាក់ ព្រមទាំងផ្តល់ សម្ភារៈ បង្រៀនដល់គ្រូ។

-បានបើកវគ្គបំប៉នបច្ចេកទេសបង្រៀនដល់គ្រូ អូ អេម អេហ្វ មួយវគ្គ ដោយសហការជាមួយការិយាល័យ អប់រំយុវជននិងកីឡាស្រុកស្នួល។

-ជារៀងរាល់ខែអង្គការ អូ អេម អេហ្វ ចុះតាមសាលារៀន ជាមួយនឹងដៃគូរបស់ការិយាល័យ អប់រំយុវជននិងកីឡាស្រុកស្នួល ដើម្បីលើកទឹកចិត្តគ្រូក្នុងការងារបង្រៀនរបស់គាត់។

លទ្ធផលសម្រេចបាន៖

| | |
|---|---|
| សិស្សសរុប | ២០៧នាក់ស្រី១១២នាក់ |
| សិស្សជាប់សរុប | ១៧៨នាក់ស្រី៩៥នាក់ |
| សិស្សធ្លាក់សរុប | ២៣នាក់ស្រី១៩នាក់ |
| សិស្សបោះបង់សរុប | ៦នាក់ស្រី៣ នាក់ |

ថវិកាចំណាយ៖

| | |
|---|---|
| ប្រាក់បៀវត្សគ្រូបង្រៀន | ៦៥០០ ដុល្លារអាមេរិកគត់ |
| ប្រាក់បន្ថែមសម្រាប់ថ្ងៃព្រហស្បតិ៍ | ៥៣១ ដុល្លារអាមេរិកគត់ |
| ប្រាក់ទ្រទ្រង់ការិយាល័យអប់រំ | ២៧០ ដុល្លារអាមេរិកគត់ |
| វគ្គបំប៉នគ្រូ | ៣៩០ ដុល្លារអាមេរិកគត់ |
| **សរុបថវិកា** | **៧៦៩១ ដុល្លារអាមេរិកគត់** |

### ២. កម្មវិធីអប់រំផ្នែកបណ្ណាល័យមធ្យមសិក្សា

-មានកម្មវិធីផ្នែកបណ្ណាល័យក្នុងប្រព័ន្ធដោយផ្តល់ប្រាក់បៀវត្សដល់បណ្ណារក្ស ១នាក់ ទាំងផ្តល់សៀវភៅ ឯកសារប្រចាំខែ។ ជារៀងរាល់សប្តាហ៍ អង្គការOMF ចុះតាមបណ្ណាល័យ ដើម្បីជួយ និងលើកទឹកចិត្តបណ្ណារក្សក្នុងការងាររបស់គាត់។

| ល.រ | បណ្ណាល័យ | សៀវភៅ | បណ្ណារក្ស |
|---|---|---|---|
| ១ | អនុវិទ្យាល័យផ្អុក | ១០០ក្បាល | ១នាក់ |

- ថវិកាចំណាយសម្រាប់កម្មវិធីអប់រំផ្នែកបណ្ណាល័យមធ្យមសិក្សា

| | |
|---|---|
| សៀវភៅឯកសារ | ៣៧០ ដុល្លារអាមេរិកគត់ |
| ប្រាក់ខែបុគ្គលិក | ៥០០ ដុល្លារអាមេរិកគត់ |
| ថវិកាសរុបចំនួន | ៨៧០ ដុល្លារអាមេរិកគត់ |

iSkysoft
Remove Watermark Now

### ៣. កម្មវិធីអប់រំផ្នែកមណ្ឌលអប់រំសម្រាប់ទាំងអស់គ្នា

-នៅឃុំស្វាយជ្រះដោយផ្តល់ មានកម្មវិធីផ្នែកបណ្ណាល័យក្រៅប្រព័ន្ធខាងមណ្ឌលអប់រំសម្រាប់ទាំងអស់គ្នា។ ជារៀងរាល់សប្តាហ៍ អង្គការOMF ចុះតាមបណ្ណាល័យដើម្បីជួយនិងលើកទឹកចិត្តបណ្ណារក្សក្នុងការងារ របស់គាត់។

| ល.រ | មណ្ឌលអប់រំសម្រាប់ទាំងអស់គ្នា | សៀវភៅ | បុគ្គលិក |
|---|---|---|---|
| ១ | ឃុំស្វាយជ្រះ | ១០០ក្បាល | ១នាក់ |

- ថវិកាចំណាយសម្រាប់កម្មវិធីអប់រំផ្នែកមណ្ឌលអប់រំសម្រាប់ទាំងអស់គ្នា

| | |
|---|---|
| សៀវភៅឯកសារ | ៥៥០ ដុល្លារអាមេរិកគត់ |
| ប្រាក់ខែបុគ្គលិក | ២៦០ ដុល្លារអាមេរិកគត់ |
| ថវិកាសរុបចំនួន | ៨១០ ដុល្លារអាមេរិកគត់ |

## ៥-**អង្គការ** SAVE THE CHILDREN

### លទ្ធផលអនុវត្តបាន

១-ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងធនធានសៀវភៅរបស់សាលាដល់គណៈកម្មការគ្រប់គ្រងសាលានៅសាលាគោលដៅ ២ វគ្គ អ្នកចូលរួម ២៥នាក់។

២-បង្រៀនគ្រូពីការជំរុញការប្រើប្រាស់សៀវភៅនៅក្នុងថ្នាក់រៀននិងលើកកម្ពស់ការសិក្សារបស់សិស្ស ២វគ្គ អ្នក ចូលរួម ២៣/០៣នាក់។

៣-ប្រជុំក្រុមឪពុកម្តាយតាមភូមិ ដោយមានការរួមបញ្ចូលពីការណែនាំពីវិធីប្រើប្រាស់សៀវភៅកុមារ និងការបង្កើតសម្ភារៈបង្រៀនកុមារដោយដៃដោយសហគមន៍ ៤ ដង ក្នុង ១០៩ភូមិ។

៤-ប្រជុំតាមដានពីការប្រើប្រាស់សៀវភៅកុមាររបស់គ្រួសារក្រោយពីទទួលបានសៀវភៅពីគម្រោងទៅបង្រៀនកូនតូច ៤ ដង ក្នុង ១០៩ភូមិ។

៥-ចុះសួរសុខទុក្ខក្រុមគ្រួសារក្នុងគម្រោងដោយបុគ្គលិក និងជនបង្គោលក្នុងសហគមន៍២ដងក្នុង១ឃុំ។

៦-បណ្តុះបណ្តាលពីការផ្លាស់ប្តូរឥរិយាបថអាណាព្យាបាលទាក់ទងនឹងគម្រោងអប់រំកុមារតូចតាមផ្ទះ ៤ ដង អ្នកចូលរួម ២០ នាក់ក្នុង១វគ្គ។

៧-សិក្ខាសាលាឆ្លុះបញ្ចាំង និងផែនការសកម្មភាពអប់រំកុមារតូចនៅថ្នាក់ឃុំជាមួយម្តាយបង្គោល និងប្រធានក្រុម ៤ដង អ្នកចូលរួម ២០ នាក់ក្នុង១វគ្គ។

៨-ប្រជុំផ្តល់មតិរវាងឪពុកម្តាយ និងគ្រូបង្រៀន។

៩-បណ្តុះបណ្តាលដល់កូនសិស្សសាលា ស្តីពីកុមារបង្រៀនកុមារ ទាក់ទងនឹងការអប់រំកុមារតូចតាមផ្ទះ។

១០-ពង្រឹងប្រព័ន្ធអប់រំរបស់រដ្ឋាភិបាល និងសហគមន៍ សម្រាប់គាំទ្រដល់ដំណើរការផ្តល់សេវា គាំពារ និងអភិវឌ្ឍកុមារតូច ប្រកបដោយគុណភាព។

១១-ចែកសៀវភៅអប់រំកុមារតូចដល់ឪពុកម្តាយតាមផ្ទះ ១៥៦២គ្រួសារស្មើនិងចំនួន៣១២៤ក្បាល។

១២-បង្កើតមណ្ឌលអានសៀវភៅតាមផ្ទះ និងផ្តល់ហិបអំណានដល់ឃុំគោលដៅ៣ហឹបអំណានដល់ឃុំគោលដៅ។

Remove Watermark Now

១៣-សាកល្បងផ្តល់មូលនិធិបន្តឲ្យឃុំចំនួន ៣ ធ្វើសកម្មភាពកម្មវិធីអប់រំកុមារតូចតាមផ្ទះដោយឃុំផ្ទាល់៣ឃុំ(សំបុក សណ្តាន់ តាម៉ៅ)។

១៤-ចុះប្រមូលទិន្នន័យឪពុកម្តាយ និងកុមារ ១ដង។

១៥-បញ្ចូលទិន្នន័យ ឪពុកម្តាយ កុមារ និងសៀវភៅដែល បានចែកដល់គ្រួសារគោលដៅ(៦៥%៣៣៩ភូមិ នៃគ្រួសារគោលដៅ១ដង។

១៦-គាំទ្រការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀន។

១៧-សិក្ខាសាលាស្តីពីការរៀបចំកិច្ចតែងការបង្រៀនសម្រាប់ថ្នាក់ទី១ដល់ទី៣ ចំនួន ៣ដង មានអ្នកចូលរួមចំនួន ៩១នាក់។

១៨-សិក្ខាសាលាស្តីពីការរៀនគណិតវិទ្យាសម្រាប់ថ្នាក់ទី ១ដល់ទី៦ ១ដងអ្នកចូលរួមចំនួន ៦២នាក់។

១៩-សិក្ខាសាលាស្តីពីបំណិនជីវិតសម្រាប់ថ្នាក់ទី៤ដល់ទី ៦ ១លើកអ្នកចូលរួម២៧/១១នាក់។

២០-សិក្ខាសាលាស្តីពីការរៀបចំ ឬការផលិតតេស្តភាសាខ្មែរ និងគណិតវិទ្យាសម្រាប់ថ្នាក់ទី១ដល់ទី៦ ១ដងមានអ្នកចូលរួមចំនួន ៦២នាក់។

២១-បានបំប៉នស្តីពីការបង្រៀន និងរៀនបែបវិជ្ជមាន១វគ្គ មានអ្នកចូលរួមចំនួន ៦២នាក់។

២២-ប្រជុំផ្សព្វផ្សាយពីសិទ្ធកុមារកិច្ចការពារកុមារ និងការអប់រំបែបវិជ្ជមានដល់គ្រួសារ និងសហគមន៍ចំនួន១វគ្គ ។

២៣-សិក្ខាសាលាស្តីពីការកាត់បន្ថយគ្រោះមហន្តរាយ និងសុខសុវត្ថិភាពសាលារៀនចំនួន ១វគ្គ ។

២៤-សិក្ខាសាលាស្តីពីសុខភាពសាលារៀនចំនួន ១វគ្គ។

២៥-បំប៉នស្តីពីតួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មការទ្រទ្រង់សាលារៀន៣វគ្គអ្នកចូលរួម២៥/៩នាក់។

២៦-ប្រជុំប្រចាំខែជាមួយគណៈកម្មការទ្រទ្រង់សាលារៀន១០លើកក្នុង១សាលា អ្នកចូលរួម៤៨/១៧នាក់។

២៧-សិក្ខាសាលាស្តីពីគណៈកម្មការថ្នាក់រៀនចំនួន ១ដង។

២៨-សិក្ខាសាលាស្តីពីការរៀបចំផែនទីសិក្សាខ្នងផ្ទះចំនួន ១ដង។

២៩-ការរៀបចំក្លឹបសិក្សានៅសហគមន៍ចំនួន ១ដង

៣០-រៀបចំក្រុមប្រឹក្សាកុមារប្រជុំជាមួយក្រុមប្រឹក្សាកុមារសាលា គោលដៅទាំង៥បានចំនួន៣លើក កុមារចូលរួមចំនួន១២០/៩៦នាក់។

៣១-វាយតម្លៃផលជះគុណភាពបរិស្ថានសិក្សាប្រកបដោយប្រសិទ្ធភាព និងការអភិវឌ្ឍសាលារៀន។

៣២-ប្រជុំផ្សព្វផ្សាយស្តីពីការយល់ដឹងអំពី បរិស្ថានគុណភាពសិក្សាប្រកបដោយប្រសិទ្ធភាពដល់គ្រូសិស្ស និងសហគមន៍១លើក អ្នកចូលរួម២២២/១៨៤នាក់។

៣៣-វគ្គបំប៉នស្តីពីស្វ័យវាយតម្លៃសាលារៀន ៣ដង អ្នកចូលរួមជាមន្ត្រីរាជការអប់រំ១០/០២នាក់ .សហគមន៍២៨៨/១៥១នាក់។

៣៤-ការផ្តល់សម្ភារឧបទេសបង្រៀន និងរៀនផ្តល់សៀវភៅរឿងនិទាន វចនានុក្រមខ្មែរភាគ១ និងភាគ២ដល់សាលាគោលដៅ៥ចំនួន១១៥៦ក្បាល ។

៣៥-ការគាំទ្រការជួសជុលហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច៥សាលាគោលដៅ។

Remove Watermark Now

៣៦-ពិនិត្យតាមដានលើដំណើរការគម្រោងជាមួយដៃគូអប់រំ។

៣៧-ពិនិត្យតាមដាន និងគាំទ្រសាលារៀនដោយមន្ទីរអប់រំ និងការិ.ស្រុក៦ដង អ្នកចូលរួម៥១/៦នាក់។

៣៨-ប្រជុំបច្ចេកទេសរវាងអង្គការសង្គ្រោះកុមារ និងមន្ទីរអប់រំ និងការិ.ស្រុក។

៣៩-គាំទ្រការត្រួតពិនិត្យ មួយសាលាម្តងក្នុងមួយខែ៦ដងក្នុង១២សាលាគោលដៅ។

៤០-ប្រជុំប្រចាំត្រីមាសជាមួយនាយកសាលា ស្តីពីការអភិវឌ្ឍសាលាបញ្ចូប្រឈម និងសំណូមពរសម្រាប់ការគាំទ្រ ២ដង អ្នកចូលរួម៣៤/០នាក់។

៤១-គាំទ្រមន្ត្រីការិយាល័យអប់រំថ្នាក់ខេត្ត/ស្រុក ដើម្បីចុះត្រួតពិនិត្យ(ការប្រជុំ និងការធ្វើទស្សនៈកិច្ចតាមសាលារៀន) ទៅលើការគ្រប់គ្រងសាលា និងគណៈកម្មការទ្រទ្រង់សាលាដើម្បីជួយកុមារក្រៅសាលាឱ្យបានចូលរៀន២វគ្គអ្នកចូលរួម៦២/៣៤នាក់ មកពី១២សាលាគោលដៅ។

៤២-ផ្តល់វគ្គបណ្តុះបណ្តាលដល់គណៈកម្មការទ្រទ្រង់សាលា ក្រុមប្រឹក្សាកុមារ គ្រូ និងនាយកសាលាស្តីពីប្រព័ន្ធគ្រប់គ្រងករណី៣៤នាក់ មកពី១២សាលាគោលដៅ១វគ្គ អ្នកចូលរួម៦២។

៤៣-ផ្តល់សម្ភារសិក្សា ឬអាហារូបករណ៍ផ្សេងៗ(ការផ្គត់ផ្គង់ផ្នែកអនាម័យ អាហារ ឯកសណ្ឋានមធ្យោបាយធ្វើដំណើរ និងតម្រូវការផ្សេងៗទៀត)ទៅឱ្យកុមារក្រៅសាលាដែលបានជ្រើសរើស។.សិស្ស ៥៣២នាក់មកពីសាលាគោលដៅ១២ (កង់ចំនួន១៣ អង្ករ១៩៦បេ ឯកសណ្ឋានសិស្ស១០៦៤កំប្លេ កាតាបសិស្ស២៣៥ សៀវភៅសរសេរ៣៥១០ក្បាលប៊ិចខៀវ១៩៥០ដើមប៊ិចក្រហម៨០៦ដើម ខ្មៅដៃ ២១៨២ដើម ជ័រលុប៥៣២ បន្ទាត់៥៣២ ប្រដាប់ចិតខ្មៅដៃ៥៣២)។

៤៤-បញ្ជូនកុមារពិការទៅមណ្ឌលស្តានីតិសម្បទាដើម្បីទទួល ឧបករណ៍ជំនួយ និងសេវារៈកាត់(រួមមាន ការគាំទ្រចំពោះការធ្វើដំណើរ ការស្នាក់នៅ និងឧបករណ៍ជំនួយ) ០១នាក់ទៅមន្ទីរពេទ្យដើម្បីពិនិត្យ និងធ្វើការវះកាត់។

iSkysoft

៤៥-បង្កើតកម្មវិធីបណ្តុះបណ្តាល និងបង្វឹកគ្រូពីបច្ចេកទេសអប់រំសម្រាប់កុមារក្រៅសាលា និងដើម្បីពង្រឹងវិធីសាស្ត្របង្រៀន និងវិធីសាស្ត្រផ្សេងៗទៀត។គ្រូបង្គោល៣នាក់ពីមន្ទីរអេយក ការិ.អយក ព្រៃកប្រសព្វ ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើអធិការកិច្ច ការគ្រប់គ្រងអាកប្បកិរិយាកុមារ និងជំនាញសម្របសម្រួលរយៈពេល១០ថ្ងៃ។

៤៦-ផ្តល់សម្ភាររៀន និងបង្រៀនដើម្បីគាំទ្របច្ចេកទេសអប់រំសម្រាប់កុមារក្រៅសាលា។.ឧបករណ៍ផលិតសម្ភារៈរៀន និងបង្រៀនសាលាគោលដៅ១២ ។

៤៧-បណ្តុះបណ្តាលពីការផលិតសម្ភារៈរៀន និងបង្រៀនដល់លោកគ្រូ អ្នកគ្រូសាលាគោលដៅ ១២១វគ្គ អ្នកចូលរួម២៧/១៨នាក់ មកពី១០សាលា។

## ៦-អង្គការ WCV

**លទ្ធផលអនុវត្តបាន៖**

១.កម្មវិធីវីឌីអូរសហគមន៍ស្តីពីគម្រោងការចុះសំបុត្រកំណើតក្នុងស្រុកចិត្របុរី មាន១០ភូមិក្នុងឃុំចំនួន៣៖ បុសលាវ គោលាប់ ចង្ក្រង់

-ប្រជាពលរដ្ឋទូទៅនិង កុមារ ចំនួន៨៤៨ក្នុងនោះស្ត្រី៥៧២បានយល់ច្បាស់ ស្តីពីការចុះសំបុត្រកំណើតក្នុងស្រុកចិត្របុរីនិងសិទ្ធិកុមារ

Remove Watermark Now

២.កម្មវិធីផ្សាយវិទ្យុស្តីពីគម្រោងចុះសំបុត្រកំណើតក្នុងស្រុកចិត្របុរី

-មានចំនួន១០ វាគ្មិនមកពី៖ សាលាខេត្ត, សាលាស្រុកចិត្របុរី, ឃុំគោលាប់, ឃុំចង្ក្រង់, ឃុំបុសលាវ។

-កម្មវិធីផ្សាយវិទ្យុបាន១០ម៉ោង និងចាក់ផ្សាយឡើងវិញបាន២៦មៅស្តីពីការចុះសំបុត្រកំណើត ក្នុងស្រុកចិត្របុរីនិងសិទ្ធិកុមារនិងមានអ្នកចូលរួម ចំនួន៖

១.ចំនួនLIKE(១១៣នាក់)

២.ចំនួន SHARE(២៣នាក់)

៣.ចំនួន VIEW(៨៧២នាក់)

៤.ចំនួនប្រិយមិត្តចូលរួម(១៩នាក់/៥ស)

៥.ចំនួន វាគ្មិន(១១នាក់ /២ស)

ការលំបាក/ បញ្ហាប្រឈម៖

-ប្រជាពលរដ្ឋមកចូលរួមយឺត

-ប្រជាពលរដ្ឋនៅមានភាពខ្មាសអៀន

-វាគ្មិនសុំប្តូរពេលវេលាផ្សាយផ្ទាល់

ទិសដៅ ឬផែនការបន្ត

បន្តធ្វើការសហការជាមួយអង្គការដៃគូផ្សេងៗដើម្បីធ្វើការផ្សព្វផ្សាយបន្ត ស្តីពីសិទ្ធិកុមារ អំពើហឹង្សាក្នុងគ្រួសារ អគ្រានុកូលដ្ឋាន...។

**៧-អង្គការ KPF**

**លទ្ធផលអនុវត្តបាន៖**

-កុមារពិការចំនួន០៨នាក់/ស្រី២ បាននឹងកំពង់ទទួលការអប់រំពិសេសនៅថ្នាក់សមាហរណកម្ម

-កុមារពិការចំនួន៣៨នាក់ស្រី១១ បាននឹងកំពុងទទួលសេវានៅតាមសហគមន៍

-កុមារពិការចំនួន២/១ស្រីបានទទួលសេវាកម្មសុខភាពពីមណ្ឌលសុខភាព

-មានការសហការណ៍ល្អជាមួយអាជ្ញធរ និងអង្គការដៃគូរក្នុងខេត្តតាមរយ:កិច្ចប្រជុំ កម្មវិធីផ្សព្វផ្សាយ និងវេទិកាសាធារណ:

-បានរៀបចំទូរ២សម្រាប់ដាកសម្ភារ:សិក្សាសិស្ស។

-បានសហការណ៍ជាមួយ អ្នកជំនាញព្យាបាលការនិយាយ និងភាសាដើម្បីផ្តល់សិក្ខាសាលា២ថ្ងៃដល់លោកគ្រូអ្នកគ្រូ និងអាជ្ញធរស្តីពីការប្រសិទ្ធភាពនៃទំនាក់ទំនងជាមួយកុមារពិការ។

-បុគ្គលិកបានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការសិក្សាស្រាវជ្រាវ និងការតស៊ូមតិ, ការសរសេររបាយការណ៍ និងសំណើថវិកាជូនម្ចាស់ជំនួយ។

**៨-អង្គការហ្គូដណេបឺសកម្ពុជា** (Good Neighbors Cambodia)

លទ្ធផលអនុវត្តបាន

១-គាំទ្រប្រាក់ឧបត្ថម្ភគ្រូ សម្រាប់ថ្នាក់ភាសាអង់គ្លេស ចំនួន៧ថ្នាក់ ៦សាលា(សាលាបាត់ហើយ២ថ្នាក់, សាលាថ្មហាលវាល ១ថ្នាក់, សាលាជើងឃ្លេ ១ថ្នាក់, សាលាខ្វាន់ជាល ១ថ្នាក់, សាលាស្អាត ១ថ្នាក់, សាលាត្រពាំងស្រែ ១ថ្នាក់)។

២-គាំទ្រសម្ភារៈសម្រាប់ធ្វើរបងសាលា ចំនួន២សាលា និង ទ្វារសាលា (សាលាស្អាត និង ខ្វាន់ជាល)

៣-គាំទ្រសម្ភារៈសម្រាប់រៀបចំអាងស្តុកទឹក ១សាលា (សាលាអញ្ចាញ)

៤-គាំទ្រប្រអប់គណនេយ្យភាព សម្រាប់៩សាលា (សាលាថ្មហាលវាល, សាលាជើងឃ្លេ, សាលាប្រវ៉ាញ, សាលាត្រពាំងស្រែក្នុង, សាលាត្រពាំងស្រែក្រៅ,សាលាស្អាត, សាលាខ្វាន់ជាល, សាលាបាត់ហើយ, សាលាអញ្ចាញ)

៥-គាំទ្រសម្ភារៈក្មេងលេង មានទោង, រអិល, រង្វង់។ល។ សម្រាប់៧សាលា (សាលាឃ្សឹមក្នុង, សាលាឃ្សឹមក្រៅ, សាលាផ្សោល, សាលាត្រពាំងស្រែក្រៅ, សាលាស្អាត, សាលាបាត់ហើយ និង សាលាអញ្ចាញ)

៦-គាំទ្រថវិកាក្នុងការចុះត្រួតពិនិត្យ និង វាយតម្លៃគុណភាពសាលា សម្រាប់១៨សាលាគោលដៅ

៧-ប្រជុំឆ្លុះបញ្ចាំងពីលទ្ធផលការងារ និង បញ្ហាប្រឈមជាមួយដៃគូពាក់ព័ន្ធ ចំនួន៥៦នាក់ស្រី១២ន

៨-គាំទ្រក្នុងការរៀបចំអំណាន នៅថ្នាក់ទី៦ សម្រាប់៧សាលា (សាលាស្អាត, សាលាមិល, សាលាស្រែថ្មី, សាលាឃ្សឹមក្រៅ, សាលាបាត់ហើយ, សាលាជើងឃ្លេ

៩-គាំទ្រថវិកាក្នុងការសាងសង់សាលាមត្តេយ្យ ៣បន្ទប់ (សាលាបាត់ហើយ, សាលាថ្មហាលវាល, សាលាស្រែរនាម)

១០-គាំទ្ររង្វាន់សម្រាប់សិស្សពូកែពីលេខ១-៦ សម្រាប់សិស្សចំនួន៣៥១សិស្ស ចំនួន៥សាលា នៅឃុំ២ធ្នូ និង ៤សាលានៅឃុំស្រែចារ។

១១-រៀបចំវគ្គសិក្ខាសាលាដល់គ្រូកិច្ចសន្យាចំនួន៦៦នាក់ស្រី២៧នាក់ វិធីសាស្ត្រនៃការបង្រៀន

១២-ផ្តល់សម្ភារៈ និង សៀវភៅ សម្រាប់បង្កើតបណ្ណាល័យ ចំនួន៨សាលា (សាលាថ្មហាលវាល, ជើងឃ្លេ, បាត់ហើយ, ខ្វាន់ជាល, ចឹង, ស្រែថ្មី, មិល, ឃ្សឹមក្រៅ)។

១៣-រៀបចំវគ្គសិក្ខាសាលាសម្រាប់គណៈកម្មការទ្រទ្រង់សាលា ចំនួន១៣នាក់ស្រី៣នាក់ពីតួនាទី និងការទំនាក់ទំនងរវាងសាលា និង សហគមន៍។

១៤-រៀបចំប្រជុំឆ្លុះបញ្ចាំងពីលទ្ធផលនៃការចុះត្រួតពិនិត្យ និង វាយតម្លៃគុណភាពសាលា ដោយមានអ្នកចូលរួមចំនួន៨១នាក់។

១៥-គាំទ្រការសាងសង់បន្ទប់ទឹកចំនួន២បន្ទប់ និង កន្លែងលាងដៃ ចំនួន៣សាលា (សាលាថ្មហាលវាល, សាលាបាត់ហើយ និង សាលាអញ្ចាញ)។

១៦-ផ្តល់ស្វូឡាបូមទឹកចំនួន៣ឈុត សម្រាប់៣សាលា (សាលាស្អាត, សាលាជើងឃ្លេ, សាលាថ្មហាលវាល)។

## III- បញ្ហាប្រឈម

### ១.បញ្ហាប្រឈមតាមអនុវិស័យ

#### ១.១-អនុវិស័យអប់រំកុមារតូច

១-ការប្រមូលកុមារមិនទាន់ឆ្លើយតបនិងចំណុចដៅប្រចាំឆ្នាំ។

២-ការរៀបចំការងាររដ្ឋបាលថ្នាក់ពុំទាន់អនុវត្តតាមស្តង់ដារអប្បបរមាកំណត់របស់ក្រសួង ។

៣-គ្រូមត្តេយ្យសិក្សាសហគមន៍ មាតា បិតាបង្ហោល និងគ្រូមត្តេយ្យសិក្សារដ្ឋមិនទាន់អនុវត្តបានតេស្តវាស់សមត្ថភាពសម្រាប់កុមារអាយុ៥ឆ្នាំ។

Remove Watermark Now

៩-គ្រូមត្តេយ្យសិក្សារដ្ឋពុំទាន់បានអនុវត្តម៉ោងបង្រៀនពេញតាមកាលវិភាគ ប្រចាំថ្ងៃ។

**១.២-អនុវិស័យបឋមសិក្សា**

១-ប្រសិទ្ធភាពនៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងនៅតាមសាលារៀនបឋមសិក្សាមួយចំនួនមិនទាន់បានល្អ គ្មានអ្នកគ្រប់គ្រងឬនាយកតែងតាំងថ្មី។

២-គ្រូបង្រៀនភាគច្រើនគ្មានកិច្ចតែងការនិងសម្ភារឧបទេសសម្រាប់បង្រៀននិងរៀន។

៣-ក្រុមពិនិត្យតាមដានថ្នាក់ស្រុក(DTMT)ពុំទាន់មានដំណើរការ។

៤-ពិបាកប្រមូលព័ត៌មានពីក្រុង / ស្រុកឬសាលារៀនមួយចំនួន។

៥-ខ្វះគ្រូរដ្ឋនៅតាមតំបន់ជួបការលំបាក។

៦-និយាមសិស្សតាមថ្នាក់នីមួយៗច្រើនពេក។

៧-សាលារៀនចំនួន៧៤,៨៥%មិនចេះទុកដាក់និងរៀបចំឯកសារឲ្យបានត្រឹមត្រូវ។

៨-សិស្សថ្នាក់ទី១ ២ ៣ ភាគច្រើនពុំទាន់ចេះអានអក្សរបានត្រឹមត្រូវនៅឡើយ។

៩-សាលារៀនភាគច្រើនពុំទាន់បានរៀបចំឯកសារតេស្តសប្តាហ៍ ប្រចាំខែ ឆមាស ។

១០-សាលារៀនចំនួន៨១,៤៧%មិនទាន់មានដំណើរការក្រុមប្រឹក្សាកុមារ។

១១-ប្រសិទ្ធភាពនៃការអនុវត្តម៉ោងសិក្សានៅបឋមសិក្សា។

១២-សមត្ថភាពគ្រូពហុភាសានៅមានកម្រិត។

១៣-ការចូលរួមពីអាណាព្យាបាលសិស្ស គណៈកម្មការទ្រទ្រង់សាលា សហគមន៍ និងអាជ្ញាធរមូលដ្ឋានក្នុងការជួយកុមារពិការនិងកុមារជួបការលំបាកនៅមានកម្រិត។

**១.៣- អនុវិស័យមធ្យមសិក្សានិងអប់រំបច្ចេកទេស**

១-ខ្វះគ្រូមុខវិជ្ជាមួយចំនួននៅអនុវិទ្យាល័យ និងវិទ្យាល័យ

-២ខ្វះសៀវភៅគ្រូ

៣-ខ្វះអាគារសិក្សា(អនុវិទ្យាល័យ)

៤-ខ្វះបន្ទប់រៀន

៥-កម្មវិធីសិក្សា និងសៀវភៅសិក្សាគោលមានការកែលម្អ ប៉ុន្តែគ្រូបង្រៀនពុំទាន់បានទទួលវគ្គបំប៉នអំពីការប្រើប្រាស់សៀវភៅថ្មី។

៦-គ្រូបង្រៀនមិនទាន់បញ្ចេញអស់សមត្ថភាព ដោយសារជីវភាពគ្រូនៅមានកម្រិត

៧-សាលាមួយចំនួនសហគមន៍មិនទាន់បានចូលរួមព្រោះពួកគាត់មិនឱ្យតម្លៃលើការអប់រំ

៨-ការទំនាក់ទំនងជាមួយ សហគមន៍ អង្គការ ជាតិ អន្តរជាតិ ក្នុងការជួយសាលាមានកម្រិត

៩-សិស្សអវត្តមានច្រើន ហើយមានការបោះបង់ការសិក្សាច្រើន។

**១.៤-អនុវិស័យអប់រំក្រៅប្រព័ន្ធ**

១-ពិបាកជ្រើសរើសគ្រូតាមសេចក្តីណែនាំរបស់ក្រសួង

២-កិច្ចសហការផ្តល់របាយការណ៍ និងឯកសារត្រឡប់មានភាពយឺតយ៉ាវ

៣-ការរៀនសូត្ររបស់សិស្សមិនសូវទៀងទាត់

៤-ថ្នាក់ដែលបានបើកដំណើរការហើយ ត្រូវបានបិទទៅវិញ

iSkysoft

Remove Watermark Now

### ១.៥- អនុវិស័យការអភិវឌ្ឍយុវជន

១-ការបំប៉នក្នុងការអភិវឌ្ឍក្រុមប្រឹក្សាយុវជន កុមារនៅមិនទាន់ឆ្លើយតប

២-ថវិកាសម្រាប់ការិយាល័យអប់រំក្រុងស្រុកចុះពិនិត្យតាមដានការងារក្រុមប្រឹក្សាយុវជនកុមារនៅមានកម្រិត

៣-របាយការណ៍ត្រឡប់នៅមិនទាន់ឆ្លើយតបពីសាលា មកការិយាល័យអប់រំ ក្រុង ស្រុកពីក្រុង ស្រុកមកមន្ទីរអប់រំខេត្ត។

៤-ពុំទាន់មានមជ្ឍមណ្ឌលយុវជនស្ម័គ្រចិត្ត ខេត្ត ក្រុង ស្រុក

៥-ការលើកទឹកចិត្តដល់អង្គភាព និងសាលារៀនមិនទាន់ឆ្លើយតប

### ១.៦- អនុវិស័យការអភិវឌ្ឍអប់រំកាយ និងកីឡា

១-ខ្វះធនធានគ្រូអប់រំកាយ និងកីឡា

២-ខ្វះទីលានសម្រាប់ហ្វឹកហាត់កីឡា

៣-ថវិកាសម្រាប់ជួសជុលទីលាននៅមានកម្រិតមិនឆ្លើយតបនិងតម្រូវការ

## ២-បញ្ហាប្រឈមការខាតគាំទ្រអនុវិស័យ

### ២.១. គណៈកម្មការសុខភាពសិក្សា

១-សាលារៀនមួយចំនួនតូចខ្វះទឹកស្អាតប្រើប្រាស់នៅរដូវប្រាំង។

២-សាលារៀនមួយចំនួនតូចខ្វះបង្គន់អនាម័យប្រើប្រាស់។

៣-សាលាមួយចំនួនមានតែបង្គន់ខ្វះការថែទាំអនាម័យ ។

៤-សាលារៀនមួយចំនួនមានបង្គន់តែខូចមិនបានជួសជុល។

៥-សិស្សមួយចំនួនតូចនៅមានទម្លាប់បន្ទោរបង់ក្រៅបង្គន់អនាម័យ(ដោយសារនៅផ្ទះរបស់គេមិនទម្លាប់ប្រើបង្គន់អនាម័យនិងបង្គន់នៅសាលាជាប់សោ )។

៦-សាលារៀនចំនួន៥៩សាលាខ្វះហិបសង្គ្រោះបឋម។

៧-លំបាកគ្រប់គ្រងការលក់នំចំណីនៅតាមសាលារៀនពុំទាន់មានសុវត្ថិភាពល្អនៅឡើយដោយសារអ្នកលក់មិនទាន់យល់ពីចំណីអាហារប្រភេទណាដែលមិនមានសុវត្ថិភាពដល់សុខភាពរបស់កុមារ។

### ២.២. សាលាគរុកោសល្យនិងវិក្រឹតការខេត្ត

១-ខ្វះបន្ទប់សិក្សា

២-ខ្វះគ្រូឯកទេស ( គំនូរ សិល្បៈ រោងជាង )

### ២.៣. ការិយាល័យផែនការ និងគ្រប់គ្រងជំនួយ

#### ១-ការងារសៀវភៅសិក្សាគោល

១-ការធ្វើតម្រូវការសៀវភៅសិក្សាគោលប្រចាំឆ្នាំ ពុំទាន់បានតាមការកំណត់របស់ក្រសួង

២-ការផ្តល់សៀវភៅសិក្សាគោលរបស់ក្រសួងពុំបានក្នុងបវេសនកាល ( សិស្សចូលរៀន ២ខែក្រោយមកទើបសៀវភៅមកដល់ ) ។

៣-ការបែងចែកសៀវភៅសិក្សាពីស្រុកទៅសាលារៀនមានការយឺតយ៉ាវ

iSkysoft

៤-នាយកសាលាទទួលសៀវភៅហើយ មិនបែងចែកសៀវភៅដល់សិស្សភ្លាមៗ នៅតែរក្សាទុកក្នុងបណ្ណាល័យ និងទីចាត់ការនៅឡើយ ។

៥-សៀវភៅសិក្សាគោលមានគុណភាពអន់ពុំអាចទុកបានតាមការកំណត់ដល់រយៈពេល៥ឆ្នាំ (ជាពិសេសក្រុបសៀវភៅបិទការអន់)។

៦-ការវេចខ្ចប់ពីគ្រឹះស្ថានពុំជាប់ល្អ

**២- ការងារផែនការ**

១-ពិបាកប្រមូលឯកសារនានាពីអ្នកពាក់ព័ន្ធ ក្នុងការធ្វើរបាយការណ៍សមិទ្ធកម្ម និងផែនការប្រតិបត្តិប្រចាំឆ្នាំ បណ្តាលអោយមានការយឺតយ៉ាវ ។

២-អ្នកពាក់ព័ន្ធ មិនទាន់យល់ច្បាស់ពីការងារផែនការប្រតិបត្តិប្រចាំឆ្នាំ និងរបាយការណ៍សមិទ្ធកម្ម

៣-ការប្រជុំរៀបចំធ្វើផែនការពុំមានការអ្នកចូលរួមពេញលេញជាពិសេសភាគច្រើនមកជាតំណាង ។

៤-ដៃគូមិនទាន់សហការបានល្អជាមួយការិយាល័យជំនាញក្នុងការដាក់សកម្មភាពក្នុងផែនការ ។

៥-ការចុះពិនិត្យតាមដាន និងគាំទ្រការធ្វើផែនការតាមសាលារៀន និងក្រុងស្រុក មិនបានផ្តល់ព័ត៌មានត្រឡប់ ។

៦-មន្ត្រីជំនាញពុំទាន់មានសមត្ថភាពមូលដ្ឋាន ក្នុងការរៀបចំផែនការ(មន្ត្រីថ្មី )

**៣- ហេដ្ឋារចនាសម្ព័ន្ធអប់រំ**

១-ការផ្តល់សំណង់អគារសិក្សាពីនាយកដ្ឋានសំណង់ មកសាលារៀន ពុំមានលិខិតជូនដំណឹង ពីប្រភពសំណង់អគារសិក្សា ។

២-ការស្នើសុំសំណង់អគារសិក្សាពីសាលាមកមន្ទីរ និងទៅនាយកដ្ឋានសំណង់ក្រសួង អប់រំ ពុំបានតាមតម្រូវការអាទិភាព ។

**៤- ផ្នែកប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ**

១-ស្រុកមួយចំនួននៅតែផ្តល់ស្ថិតិប្រចាំឆ្នាំមានការយឺតយ៉ាវ ។

២-សាលាមួយចំនួនពុំទាន់យកចិត្តទុកដាក់ក្នុងផ្តល់ស្ថិតិប្រចាំឆ្នាំឱ្យបានទាន់កាលកំណត់

៣-មន្ត្រីជំនាញទទួលស្ថិតិខេត្ត ក្រុង/ស្រុក នៅពុំទាន់មានសមត្ថភាពជំនាញ ជាពិសេសការប្រើប្រាស់កុំព្យូទ័រ ។

៤-មន្ត្រីជំនាញស្ថិតិពុំទាន់មានសមត្ថភាពគណនា និងវិភាគសូចនាករអប់រំនៅឡើយ

## ២.៤. ការិយាល័យបុគ្គលិក

១-ខ្វះមន្ត្រីជំនាញផ្នែកទិន្នន័យ ព្រោះមន្ត្រីដែលកាន់សព្វថ្ងៃ មានតែ១នាក់ គ្រប់គ្រងបៀវត្សផង ទិន្នន័យផង ដែលធ្វើឲ្យការិយាល័យមានភាពលំបាកក្នុងការគ្រប់គ្រងស្ថិតិបុគ្គលិកអប់រំ ។

២-ខ្វះថវិកាសម្រាប់ចុះតាមដានសាលារៀន ធ្វើឲ្យមានការលំបាកក្នុងការតាមដាននិងទទួលយកព័ត៌មានផ្សេងៗពីស្រុក និងសាលារៀន ។

៣-សាលានៅតំបន់ជួបការលំបាកខ្វះគ្រូបង្រៀនធ្វើឲ្យការប្រើប្រាស់គ្រូជាប់កិច្ចសន្យានិងថ្នាក់គួបមានការកើនច្រើន។

៤-គ្រូលើសនៅតំបន់ប្រជុំជន (ការពង្រាយគ្រូអនុវត្តតាមគោលការណ៍ស្ម័គ្រចិត្ត ។

Remove Watermark Now

## ២.៥. ការិយាល័យគណនេយ្យ សម្ភារ និងទ្រព្យសម្បត្តិរដ្ឋ

១-កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុលឿនពេក មានការផ្លាស់ប្តូរលិខិតបទដ្ឋាននៅកណ្តាលឆ្នាំអនុវត្តថវិកា និងការណែនាំពីនីតិវិធីមួយចំនួននៅមិនទាន់ច្បាស់លាស់ ។

២-ការិយាល័យជំនាញមួយចំនួន មិនសូវយកចិត្តទុកដាក់ក្នុងការរៀបចំផែនការថវិកា ឱ្យបានសមស្របតាមផែនការសកម្មភាព ដែលត្រូវអនុវត្តប្រចាំឆ្នាំរបស់ខ្លួន។

៣-ក្រសួងដែលមានសមត្ថកិច្ចត្រួតពិនិត្យការងារហិរញ្ញវត្ថុ ច្រើនក្រុមពេក ធ្វើឱ្យអ្នកអនុវត្តនៅថ្នាក់ក្រោមជួបការលំបាក ។

៤-អចលនទ្រព្យ(ដីធ្លី និងអគារ )ស្ទើរតែទាំងអស់ពុំទាន់មានប្លង់ និងប័ណ្ណកម្មសិទ្ធិ

៥-ការស្នើសុំជម្រះបញ្ជីទ្រព្យសម្បត្តិ ទៅក្រសួងមានការយឺតយ៉ាវ ជាក់ស្តែង(ម៉ូតូ សុំទៅ ៣ ឆ្នាំហើយមិនទាន់ចេញ)

## ២.៦. ការិយាល័យអធិការកិច្ច

១-ការចុះអធិការកិច្ចសាលារៀនមិនបានតាមកាលកំណត់ មូលហេតុចូលរួមសិក្ខាសាលាការបំប៉នសមត្ថភាពអធិការស្តីពីការកែលំអសាលារៀន ការធ្វើតេស្តវាយតម្លៃថ្នាក់ជាតិថ្នាក់ទី៨មុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា រូបវិទ្យា និងតេស្តវាយតម្លៃ PISA-D ជាកម្មវិធីថ្នាក់ជាតិ។

២-សាលារៀនមិនទាន់យល់ដឹងពីស្វ័យវាយតម្លៃសាលារៀន។

៣-ខ្វះអធិការអប់រំសម្រាប់ចុះអធិការកិច្ចសាលារៀនតាមកាលកំណត់។

៤-ការធ្វើអធិការកិច្ចសាលារៀន អធិការមិនទាន់មានប័ណ្ណព័ត៌មានសាលារៀន(School Data sheet ) ច្បាស់លាស់។

៥-ក្រុមពិនិត្យ តាមដានថ្នាក់ក្រុង ស្រុក(DTMT) មិនសូវមានសកម្មភាពក្នុងការពិនិត្យ តាមដានសាលារៀន (អធិការកិច្ចផ្ទៃក្នុង)។

៦-នាយកសាលារៀនមិនបានធ្វើរបាយការណ៍អធិការកិច្ចគ្រូមកមន្ទីរអប់រំ

## ២.៧. ការិយាល័យរដ្ឋបាល

១-ខ្វះថវិកាដើម្បីរៀបចំប័ណ្ណសារគ្រប់គ្រងឯកសាររបស់អង្គភាព

២-មន្ត្រីគ្រប់គ្រងឯកសារមិនទាន់មានសមត្ថភាពប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា

៣-លិខិតចេញក៏ដូចជាលិខិតចូលនៅមានមួយចំនួនតូចមិនចូលតាមច្រករដ្ឋបាលដែលជាហេតុធ្វើឲ្យចរន្តលិខិតមិនចំទិសដៅហើយដែលការិយាល័យជំនាញក្តាប់មិនបាន។

៤-យន្តការនៃការចរាចរចរន្តលិខិតពុំទាន់មានលក្ខណៈល្អប្រសើរនៅឡើយ។

## ២.៨. ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក

### ១. ស្រុក ឆ្លូង

១.កុមារអាយុក្រោម៥ឆ្នាំទាំងមត្តេយ្យសិក្សារដ្ឋ ទាំងមត្តេយ្យសិក្សាសហគមន៍មករៀនមិនបានទៀងទាត់ ។

២.បច្ចេកទេសបង្រៀនទាំងបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិពុំទាន់មានភាពល្អប្រសើរ ដោយ

Remove Watermark Now

មូលហេតុ គ្រូភាគច្រើនពុំមានកិច្ចតែងការបង្រៀនគ្រប់មុខវិជ្ជា ។

៣.គ្រូបង្រៀនទាំងបឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិមួយចំនួនតូច បង្រៀនមិន ទាន់កម្មវិធីសិក្សា ។

៤.កិច្ចការងាររដ្ឋបាលរបស់នាយកសាលាទើបតែងតាំងថ្មីមានភាពខ្វះចន្លោះច្រើន ។

៥.កិច្ចបញ្ជិកាគណនេយ្យPB និងSIG តាមសាលារៀននៅតែមានការខុសឆ្គង ។

៦.សិស្សអក្ខរកម្មមករៀនមិនទៀងទាត់ ។

៧.ក្រុមប្រឹក្សាកុមារ និងយុវជនតាមគ្រឹះស្ថានសិក្សាដំណើរការបានតិចតួច ។

៨.លោកគ្រូអ្នកគ្រូឈរថ្នាក់មិនបានយកចិត្តទុកដាក់សហការ ការងារក្រុមប្រឹក្សាយុវជន និងកុមារ។

៩.ពិបាកជ្រើសរើសគ្រូអក្ខរកម្មតាមសេចក្តីណែនាំរបស់ក្រសួង ។

១០.គ្រូអក្ខរកម្មផ្តល់ឯកសារ និងរបាយការណ៍ត្រឡប់មានភាពយឺតយ៉ាវ។

១១.សិស្សអក្ខរកម្មមករៀនមិនទៀងទាត់។

**២. ស្រុក ចិត្របុរី**

១.ខ្វះអគារសិក្សា និងអាគារមួយចំនួនចាស់ទ្រុឌទ្រោម។

២.ខ្វះគ្រូបង្រៀននៅបឋមសិក្សាតាមសាលាតំបន់ជួបការលំបាក និងផ្នែកមធ្យមសិក្សាផ្តល់គ្រូមិនត្រូវតាមឯកទេស។

៣. លោកគ្រូ អ្នកគ្រូមួយចំនួនបង្រៀន គ្មានកិច្ចតែងការបង្រៀន និងរៀន ព្រមទាំងសម្ភារៈឧបទេស

៤. សាលារៀន និងសហគមន៍ភាគច្រើនមិនសូវមានទំនាក់ទំនងល្អជាមួយគ្នា។

**៣. ក្រុង ក្រចេះ**

១-នាយកសាលាបង្រៀនផង និងគ្រប់គ្រងផង (បឋមកោះទ្រង់ និងចុងកោះទ្រង់)

២-ការរៀបចំកិច្ចការបង្រៀនមិនទាន់បានគ្រប់មុខវិជ្ជា

៣-សាលារៀនភាគច្រើនក្រុមប្រឹក្សាកុមារពុំទាន់មានសកម្មភាព

៤-សិស្សចូលរៀនច្រើន តែខ្វះបន្ទប់រៀន (សម្រាប់មត្តេយ្យសិក្សា)

៥-តុ កៅអីសិស្ស មានទំហំធំៗ មិនសមស្របកុមារតូចអង្គុយរៀន

**៤. ស្រុក ព្រែកប្រសព្វ**

១-ខ្វះបន្ទប់រៀន ខ្វះតុសិស្ស ខ្វះគ្រូបង្រៀន មានសិស្សច្រើនលើសនិយាម(មត្តេយ្យ)

២-ភាគរយសិស្សត្រួតថ្នាក់ខ្ពស់បឋមសិក្សា ១៤%

៣-ភាគរយសិស្សបោះបង់ផ្នែក មធ្យមសិក្សាបឋមភូមិ ១០.២៩% និងមធ្យមសិក្សាទុតិយភូមិ ៧.១៣%

៤-សាលារៀនភាគច្រើនបំពេញតារាងឧបករណ៍វាយតំលៃប្រព័ន្ធពិនិត្យតាមដានពុំទាន់បានត្រឹមត្រូវ

៥-ខ្វះសៀវភៅសិក្សាគោល

៦-ថ្នាក់អក្ខរកម្មពិបាកក្នុងការប្រមូលសិស្សចូលរៀន

៧-ខ្វះទីលានហ្វឹកហាត់កីឡា

៨-សិស្សថ្នាក់ទី១,២,៣ ភាគច្រើនពុំទាន់ចេះអានអក្សរបានត្រឹមត្រូវនៅឡើយកិច្ចបញ្ជីការ

គណនេយ្យ តាមសាលារៀនមានភាពខ្វះចន្លោះច្រើន

**៥. ស្រុក សំបូរ**

១-ខ្វះគ្រូបង្រៀនក្របខ័ណ្ឌ កម្រិតមត្តេយ្យ បឋម និងមធ្យមសិក្សា

២-សាលាមួយចំនួនពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ ក្នុងការងារគ្រប់គ្រងនិងការងាររដ្ឋបាលសាលារៀន និងមានភារកិច្ចបង្រៀនផង

៣-កត្តាភូមិសាស្ត្រ និងការសង់ផ្ទះនៅរាយប៉ាយទៅតាមដីស្រែចម្ការឆ្ងាយពីសាលារៀន និង ទំនៀមទម្លាប់ប្រពៃណីជនជាតិដើមភាគតិចតាមតំបន់ធ្វើឱ្យកុមារមក រៀនពុំទៀងទាត់

៤-គ្រូមត្តេយ្យសិក្សាសហគមន៍ និងម្តាយបង្គោលមានការផ្លាស់ប្តូរ

**៦. ស្រុក ស្នួល**

១-អ្នកគ្រូមតេយ្យរដ្ឋខ្វះសៀវភៅសិក្សាគោល និងសម្ភារបង្រៀន

២-គ្រូកិច្ចសន្យាខ្វះបទពិសោធន៍ក្នុងការបង្រៀនក្មេង មិនចេះធ្វើកិច្ចតែងការបង្រៀន ។

៣-គ្រូបង្រៀនមិនមានកិច្ចតែងការ

៤-គ្មានសម្ភារបង្រៀន

៥-មិនរៀបចំរដ្ឋបាលថ្នាក់

៦-ថ្នាក់រៀនគ្មានរៀបចំបរិស្ថាន

៧-របាយការណ៍មិនទាន់ពេលកំណត់

៨-ខ្វះអគារបន្ទប់សាលា(គ្មានសុវត្ថិភាព)ជាមូលហេតុមិនអាចអនុវត្តន៍កម្មវិធីសាលាកុមារមេត្រី

៩-ខ្វះបុគ្គលិក

១០-គ្មានការរៀបចំតុបតែងលម្អថ្នាក់រៀនតាមបែបកុមារមេត្រី

១១-ចេញនិងចូលរៀនមិនទៀងទាត់មិនឯកភាពគ្នា

១២-គ្មានរៀបចំកម្រងស្នាដៃសិស្ស

១៣-សាលារៀនពុំមានទិន្នន័យសិស្ស និងកុមារត្រឹមត្រូវ

១៤-កុមារចូលរៀនមិនទាន់បានសម្រេចតាមគោលដៅ(កម្រិតទាប)

១៥-សាលាគ្មានក្រុមបណ្តុញខ្នងផ្ទះ

១៦-សាលាមួយចំនួនមានអត្រាត្រួតថ្នាក់ខ្ពស់

១៧-អត្រាឆ្លងភូមិសិក្សាទាប

១៨-សាលាពុំមានរៀបចំតេស្តសិស្សប្រចាំសប្តាហ៍ ខែ ឆ្នាំ

១៩-ខ្វះអគារសិក្សា

២០-ខ្វះតុសិស្ស

២១-គ្រូមួយចំនួនបង្រៀនមិនទាន់ពេលវេលា

២២-សាលាមួយចំនួន ខ្វះតុសិស្ស

២៣-គ្រូមួយចំនួនបង្រៀនមិនទាន់ពេលវេលា

២៤-សាលាមួយចំនួនអនុវត្តន៍ម៉ោងចេញ និងម៉ោងចូលមិនទាន់ត្រឹមត្រូវ

២៥-សាលាមួយចំនួនមិនទាន់បានរៀបចំបរិស្ថានក្នុងសាលាបានល្អ

២៦-ខ្វះបង្គន់អនាម័យ

២៧-សហគមន៍មិនសូវយកចិត្តទុកដាក់ជាមួយសាលា

២៨-ពិបាកក្នុងការប្រមូលសិស្ស

២៩-មាតាបិតាធ្វើការចំណាកស្រុកច្រើន (ចំនួនបោះបង់មានតែឈ្មោះ តែគ្មានមនុស្ស) ។

៣០-សាលារៀនមិនបញ្ជូលរបាយការណ៍ទាន់ពេលវេលាធ្វើអោយការបូកសរុបរបាយការណ៍របស់ការិយាល័យមិនបានតាមការកំណត់របស់មន្ទីរ និងក្រសួង ។

៣១-នាយកសាលាមួយចំនួនថ្មី មិនមានបទពិសោធន៍ក្នុងការកសាងផែនការអភិវឌ្ឍន៍សាលារៀន

៣២-នាយកសាលាមួយចំនួនពុំមានសមត្ថភាពរៀបចំផែនការអភិវឌ្ឍន៍សាលារៀន ។

៣៣-លោកនាយកសាលាបញ្ជូនរបាយការណ៍មិនទាន់ពេលវេលា

៣៤-សាលាមួយចំនួនមិនដែលធ្វើការបែងចែកក្រុមប្រឹក្សាកុមារ

៣៥-សាលាខ្វះការបែងចែក នាំអោយសិស្សគ្មានវិន័យ និងសណ្តាប់ធ្នាប់ល្អ

៣៦-ខ្វះសម្ភារក្នុងការហ្វឹកហាត់

៣៧-សាលាមួយចំនួនគ្មានទីលានស្តង់ដារប្រកួត

៣៨-សិស្សមិនទាន់ចេះពីច្បាប់លេងកីឡា

៣៩-ខ្វះគ្រូអប់រំ និងកីឡា

## ២.៩. ដៃគូអភិវឌ្ឍ

**១-អង្គការ** KAFDOC

-ការចូលរួមរបស់មាតាបិតាកុមារ គណៈកម្មការទ្រទ្រង់សាលា ក្នុងការតាមដានការសិក្សា របស់កូនមិនបានពេញលេញ។

-ការទំនាក់ទំនងរវាងសាលារៀន និងមាតាបិតាកុមារ និងសហគមន៍នៅមិនទាន់ល្អនៅឡើយ។

-ការរំលោភបំពានសិទ្ធិកុមារ(ការការពារ និង កេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ) នៅក្នុងសហគមន៍ និង អំពើហិង្សាក្នុងគ្រួសារ នៅតែកើតមាន។

-ការប្រើប្រាស់សម្ភារៈពង្រឹងអំណានដែលបានផ្តល់ជូននៅមានកម្រិត(ដោយខ្លះមិនទាន់បានប្រើប្រាស់)

**២. អង្គការ** KPF

១-ផ្ទះកុមារពិការនៅឆ្ងាយពីមណ្ឌល

២-កុមារពិការភាគច្រើនមានបញ្ហាសុខភាព និងអនាម័យ

៣-ការផ្សព្វផ្សាយពីបញ្ហាកុមារពិការមិនទាន់បានទូលំទូលាយនៅថ្នាក់មូលដ្ឋាន

៤-ក្រុមគ្រួសារកុមារពិការមានកម្រិតជីវភាពខ្វះខាត

-សមត្ថភាពបុគ្គលិកនៅមានកម្រិត

# IV- ទិសដៅឆ្នាំសិក្សា២០១៦- ២០១៧

## ១. ទិសដៅតាមអនុវិស័យ

### ១.១-អនុវិស័យអប់រំកុមារតូច

១-ពង្រីកថ្នាក់មត្តេយ្យសិក្សារដ្ឋនៅឆ្នាំសិក្សា ២០១៧-២០១៨ ចំនួន ១០ថ្នាក់ ។

២-ពង្រីកថ្នាក់មត្តេយ្យសិក្សាសហគមន៍ចំនួន០៥ថ្នាក់។

៣-បើកវគ្គបំប៉នគ្រូមត្តេយ្យសិក្សារដ្ឋលើការងារបច្ចេកទេសនិងរៀបចំថ្នាក់តាមស្តង់ដារ។

